ការបោះពុម្ពផ្សាយ

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

VOL. 01



## ការវិវត្តនៃលទ្ធិ
## ប្រជាធិបតេយ្យ

# ក្រុមប្រឹក្សាឃុំកម្ពុជា
# ក្នុងអាណត្តិទីមួយ

ស្រាវជ្រាវដោយ

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

ឧសភា
២០០៧

Konrad
Adenauer
Stiftung

ការបោះពុម្ពផ្សាយ Vol. 01

## ការវិវត្តនៃលទ្ធិ
## ប្រជាធិបតេយ្យ

# ក្រុមប្រឹក្សាឃុំកម្ពុជា
# ក្នុងអាណត្តិទីមួយ

**ស្រាវជ្រាវដោយ**

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

**បោះពុម្ពដោយ**

Konrad Adenauer Stiftung

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

ព្រះរាជាណាចក្រកម្ពុជា

**អំពីមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ**

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរគឺជាមូលនិធិនយោបាយមួយរបស់ប្រទេសអាល្លឺម៉ង់ ហើយឈ្មោះរបស់មូលនិធិ គឺជាឈ្មោះរបស់លោកអធិការបតីដំបូងនៃប្រទេសអាល្លឺម៉ង់ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ផ្តល់ជូននូវការប្រឹក្សា ការបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ចល្អជាមួយនឹងទស្សនវិស័យជំរុញឱ្យមានស្ថាប័ននយោបាយប្រជាធិបតេយ្យ និងគោលនយោបាយផ្សេងៗ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ធ្វើសកម្មភាពនៅក្នុង១២០ប្រទេសទូទាំងពិភពលោក។ ពាក់កណ្តាលនៃសកម្មភាពទាំងអស់របស់មូលនិធិ ត្រូវបានធ្វើយ៉ាងខ្ជាប់ខ្ជួននៅក្នុងប្រទេសអាល្លឺម៉ង់។ ការិយាល័យនៅប្រទេសកម្ពុជាបានបង្កើតឡើងនៅឆ្នាំ១៩៩៤។ ដៃគូរបស់មូលនិធិរួមមាន រដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងជំនាញមួយចំនួន បក្សនយោបាយដែលមានអសនៈក្នុងរដ្ឋសភា ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិលដទៃទៀត។ ក្នុងឆ្នាំថ្មីៗកន្លងទៅនេះ មូលនិធិបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់គាំទ្រដល់វិមជ្ឈការប្រជាធិបតេយ្យ។

**ការបោះពុម្ពផ្សាយស្តីពីការវិវត្តនៃលទ្ធិប្រជាធិបតេយ្យ**

នៅក្នុងការផ្សាយលើកនេះ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ បានចងក្រងឯកសារដែលពាក់ព័ន្ធ ផ្តល់ឱ្យពីកិច្ចសហប្រតិបត្តិការជាមួយដៃគូនៅកម្ពុជាតាមកម្មវិធីការងារជំនាញនីមួយៗ។

©រក្សាសិទ្ធិ ២០០៧ ដោយមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ, ព្រះរាជាណាចក្រកម្ពុជា

**ស្រាវជ្រាវដោយ:**
វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

**បោះពុម្ពដោយ:**
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ
ផ្ទះលេខ ៤, ផ្លូវលេខ ៤៦២,
ខ័ណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៩៤៤
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៣ ៣៦៣ / ៧២៦ ២២១
ទូរសារ : (៨៥៥-២៣) ២១៣ ៣៦៤
អ៊ីម៉ែល : office@kas-cambodia.com
គេហទំព័រ : www.kas.de/kambodscha

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

ISBN-13: 978-99950-880-0-2

# អារម្ភកថា

មានការបោះពុម្ពផ្សាយជាច្រើនស្តីពីការងាររដ្ឋនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នៅកម្ពុជា ចាប់ពីពេលដែលមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យក្នុងឆ្នាំ២០០២ ដើម្បីជ្រើសរើសក្រុមប្រឹក្សាតាមលក្ខខណ្ឌប្រជាធិបតេយ្យ។ ការសិក្សាមួយចំនួនបានត្រូវធ្វើឡើងបន្ទាប់ពីដំណើរការនៃការកែទំរង់បានចាប់ផ្តើម។ ទាំងនេះ គឺជាការបង្ហាញនូវទំហំនិងការយកចិត្តទុកដាក់ក្នុងការគាំទ្ររបស់ប្រទេសកម្ពុជា និងអង្គការបរទេសដែលមានគោលបំណងខុសៗគ្នាក្នុងការតំរង់ទិស។ ចំណាប់អារម្មណ៍របស់មូលនិធិ និងដៃគូរ យល់ឃើញថា ភាពរីកចំរើនដែលទទួលបានតាំងពីឆ្នាំ២០០២ មានលក្ខណៈជាវិជ្ជមាន។ ប៉ុន្តែវាហាក់នៅមានការលំបាកនឹងយល់ពីទំហំនៃការកែទំរង់នៅថ្នាក់មូលដ្ឋាននេះ និងជំរាបបញ្ហាទាំងអស់នេះដល់អ្នកមកកាន់ដំណែងថ្មី។

ខ្ញុំមានចំណាប់អារម្មណ៍ថា របាយការណ៍នេះបានសំរេចនូវភាគច្រើននៃគោលបំណងនេះ ហើយមានលក្ខណៈគ្រប់គ្រាន់ដោយពុំចាំបាច់មានតំណាង និងការព្យាយាមបង្ហាញសំអាងផ្សេងៗឡើយ។ របាយការណ៍បានបង្ហាញពីជោគជ័យ និងបទពិសោធន៍មិនទាន់បានពេញចិត្តទាំងស្រុងនៅឡើយ។ លទ្ធផលនេះត្រូវបានផ្តល់ឱ្យដ៏ជាក់លាក់តាមរយៈការធ្វើបទសម្ភាសន៍ចំនួន២៧ តាមរយៈការបំពេញតារាងសំនួរចំនួន៦៨ និងតាមរយៈការស្រង់មតិចំនួន២៧១។

ជំហានដំបូងឆ្ពោះទៅរកស្វ័យគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន បានផ្តល់ឱ្យនូវជំនាញមួយចំនួន ការលើកទឹកចិត្តជាច្រើន និងការសង្ឃឹមដ៏ខ្ពស់។ សូមឱ្យអាណត្តិទី២នេះសមាជិកក្រុមប្រឹក្សាទាំងអស់បានទទួលការសាទរ និងការគាំទ្រដូចនៅក្នុងអាណត្តិទី១ដូច្នេះដែរ។

ជាមួយរបាយការណ៍នេះមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ បានចាប់ផ្តើមចងក្រងឯកសារតាមកាលវេលានីមួយៗ។ ការរៀបរៀងកំរងឯកសារនេះ មានទិសដៅចែក

រំលែកនូវទិន្នផលការងាររបស់ដៃគូរ ក៏ដូចជារបស់មូលនិធិ។ ខ្ញុំសង្ឃឹមថាការបោះពុម្ពជាសេរីលើកទីមួយនេះនឹងទទួលបាននូវការសាទរ និងបំពេញបាននូវសេចក្ដីត្រូវការ។

សូមថ្លែងអំណរគុណ និងកោតសសើរចំពោះវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ និងអ្នកស្រី ណៃ ឌីណា ជានាយិកាប្រតិបត្តិព្រមទាំងបុគ្គលិក ដែលជាដៃគូរដ៏សំខាន់មួយក្នុងចំណោមដៃគូរផ្សេងៗទៀត ដែលបានខិតខំប្រឹងប្រែងធ្វើការងារយ៉ាងសកម្មអស់រយៈពេលជាច្រើនឆ្នាំនៅលំដាប់ឃុំ-សង្កាត់ ហើយត្រូវបានបញ្ចេញឱ្យដឹងដោយរបាយការណ៍ដ៏មានសារៈសំខាន់នេះ។ សូមអានឯកសារនេះ បើសិនជាលោកអ្នកមានបំណងចង់ស្វែងយល់ឱ្យបានច្រើន អំពីការងារក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានបញ្ចប់អណត្តិទីមួយរបស់ខ្លួន។

**Wolfgang MEYER**
តំណាងប្រចាំប្រទេស
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

# មាតិកា


បុព្វកថា.......................................................................................................៩

សេចក្តីផ្តើម.................................................................................................១១

១. ការប្រមូលទិន្នន័យ.................................................................................១២

២. កិច្ចសម្ភាសន៍ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់........................១២

៣. សំនួរចំពោះសមាជិកក្រុមប្រឹក្សាឃុំ.......................................................១៣

៤. សំនួរចំពោះប្រជាពលរដ្ឋ.........................................................................១៤

តួនាទី ភារកិច្ច និង ការទទួលខុសត្រូវ..........................................................១៥

សមត្ថភាពក្នុងការអនុវត្តវិមជ្ឈការ................................................................១៧

១. ការយល់ដឹងអំពីវិមជ្ឈការ.......................................................................១៧

២. វគ្គបណ្តុះណ្តាល.....................................................................................១៩

៣. អនុសាសន៍សំរាប់ការបណ្តុះបណ្តាលនាពេលអនាគត..............................២២

៤. ហិរញ្ញវត្ថុ.............................................................................................២៥

រចនាសម្ព័ន្ធ និង ការគ្រប់គ្រងរដ្ឋបាល.........................................................៣០

១. សមាជិកក្រុមប្រឹក្សាស្ត្រី..........................................................................៣០

២. កិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយ........................................៣៣

៣. ការសហការជាមួយនឹងមេភូមិ.................................................................៣៤

៤. ដំណោះស្រាយជម្លោះ.............................................................................៣៦

ការចូលរួមរបស់ប្រជាពលរដ្ឋ.........................................................................៣៩

១. ការចូលរួមរបស់ប្រជាពលរដ្ឋ...................................................................៣៩

២. ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះការចូលរួម............................................៤២

៣. ស្សនៈរបស់ក្រុមប្រឹក្សាពីការចូលរួម.......................................................៤៥

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ........................................ ៤៨
១. ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ........................................ ៤៨
២. ទស្សនៈរបស់ក្រុមប្រឹក្សា ........................................ ៥២
៣. ទស្សនៈប្រជាពលរដ្ឋចំពោះផែនការអភិវឌ្ឍន៍ ........................................ ៥៣
សេចក្តីសន្និដ្ឋាន ........................................ ៥៦

# បុព្វកថា

វិមជ្ឈការជារបត់ផ្លូវមួយសំខាន់ណាស់ សំរាប់ប្រទេសកម្ពុជា នៅពេលដែលអាជ្ញាធរថ្នាក់កណ្តាលបានសំរេចធ្វើការផ្ទេរនូវសិទ្ធិអំណាច និងធនធានមួយចំនួនទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាតំណាងរបស់ប្រជាពលរដ្ឋតាមការបោះឆ្នោតជាសកល។ នេះសរឱ្យឃើញ នូវឆន្ទៈនយោបាយមួយនៅក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន នៅក្នុងការជម្រុញឱ្យមានការចូលរួមធ្វើការសំរេចចិត្តនានា ដែលជាតម្រូវការផ្ទាល់របស់មូលដ្ឋាន និងជាចំណែកមួយនៃការទទួលខុសត្រូវរបស់ពលរដ្ឋនៅក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។

ទោះបីជានៅក្នុងអណត្តិទីមួយនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ជួបនៅបញ្ហាប្រឈមជាច្រើន ចំពោះការបំពេញនូវភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក៏ជាជំហានមួយទៅមុខជាវិជ្ជមាននៅក្នុងការកសាងប្រជាធិបតេយ្យដ៏ក្មេងខ្ចី និងជាបទពិសោធន៍សំរាប់ការអនុវត្តនៅក្នុងអាណត្តិទីពីរ។ នៅក្នុងការរៀបរៀងនូវឯកសារនេះ ជាទស្សនៈទានមួយចំនួនចំពោះអ្វីដែលវិទ្យាស្ថានបានមើលឃើញ នៅក្នុងការចូលរួមចំណែក នៅក្នុងការបណ្តុះបណ្តាលក៏ដូចជា ការចូលរួមនៅក្នុងការងារមួយចំនួនរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងការអនុវត្តនយោបាយវិមជ្ឈការ។ សមិទ្ធិផលដែលក្រុមប្រឹក្សាឃុំ-សង្កាត់បានសំរេចបាននៅក្នុងអាណត្តិនេះអាចចាត់ ទុកថាជាស្នាដៃមួយដ៏គួរឱ្យកត់សំគាល់ បើប្រៀបធៀបទៅនឹងស្ថានភាពដែលក្រុមប្រឹក្សាឃុំ-សង្កាត់ បំពេញការងារដែលមានការខ្វះខាតទាំងលើផ្នែកធនធានមនុស្ស ថវិកា ក៏ដូចជាបច្ចេកទេសជំនាញ។

វិទ្យាស្ថានសង្ឃឹមថាឯកសារនេះ ជាការរួមចំណែកមួយនៅក្នុងការជំរុញឱ្យកាន់តែប្រសើរឡើងនូវការអនុវត្តនយោបាយវិមជ្ឈការ នៅក្នុងអាណត្តិទីពីរនៃក្រុមប្រឹក្សាឃុំ-សង្កាត់។ វិទ្យាស្ថានសូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅ ចំពោះមូលនិធិ ខុដរ៉ាដ អាដិនណៅអ៊ែររបស់ប្រទេសអាល្លឺម៉ង់ ដែលផ្តល់ថវិកាដល់វិទ្យាស្ថាននៅក្នុងការបណ្តុះ

បណ្តាលក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្ត្រីបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ដូចជាការធ្វើការស្រាវជ្រាវ និងបោះពុម្ភឯកសារនេះ។ សូមថ្លែងអំណរគុណផងដែរដល់សមាជិកសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ដែលបានផ្តល់ការសហការជាមួយវិទ្យាស្ថាននៅក្នុងការងារបណ្តុះបណ្តាល និងដូចជាការអនុញ្ញាតឱ្យវិទ្យាស្ថានបានជួបសម្ភាសន៍ និងអ្នកពាក់ព័ន្ធឯទៀត ជាពិសេសកញ្ញា Maria Fosnaes និង Sabine Hofer និស្សិតសកលវិទ្យាល័យ Aalborg ប្រទេសដាណឺម៉ាក ដែលបានរួមចំណែកនៅក្នុងការរៀបរៀងឯកសារនេះ។

ណៃ ឌីណា
នាយិកាប្រតិបត្តិ
វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

# សេចក្តីផ្តើម

គោលបំណងនៃរបាយការណ៍នេះ គឺធ្វើការវាយតំលៃពីដំណើរការនៃការអនុវត្ត នយោបាយវិមជ្ឈការ និងការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងអំលុងពេល ប្រាំឆ្នាំដំបូងនៃអាណត្តិទីមួយ។ ដោយសារមានការវាយតំលៃជាទូទៅមួយរបស់គណកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ ពីការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានធ្វើឡើងហើយនោះ ហើយការវាយតម្លៃនោះមិនបានផ្តោតទូលំទូលាយ វិទ្យាស្ថានបានផ្តោតលើចំនុចប្រាំដូចខាងក្រោមនេះ ។ ការវាយតំលៃនេះមានគោលបំនងធ្វើការបរិយាយយ៉ាងល្អិតល្អន់ពីការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ លទ្ធផលដែលបានបង្ហាញនាពេលនេះ បានផ្អែកលើការប្រមូលទិន្នន័យក្នុងរាជធានីភ្នំពេញ ព្រមទាំងនៅខេត្តតាកែវ និងកំពត។ ការជ្រើសរើសខេត្តទាំងនេះ គឺដោយសារវិទ្យាស្ថានមានទំនាក់ទំនងសហប្រតិបត្តិការអស់ រយៈពេលយូរមកហើយជាមួយនឹងឃុំក្នុងខេត្តទាំងនោះ។

ការវាយតំលៃនេះបានផ្តោតលើចំនុច៥ដូចខាងក្រោម :

១- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

២- សមត្ថភាព និងលទ្ធភាពក្នុងដំណើរការអនុវត្តវិមជ្ឈការ

៣- រចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់

៤- ការចូលរួម និងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការវិមជ្ឈការ

៥- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដំណើរការ និងការអភិវឌ្ឍន៍

ចំពោះផ្នែកទីមួយ។ ការវាយតំលៃនឹងផ្តោតលើការប្រឈមមុខទាំងឡាយដែល ក្រុមប្រឹក្សាឃុំ-សង្កាត់ជួបប្រទះ និងឥទ្ធិពលនៃដំណើរការវិមជ្ឈការចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់។ គោលបំណងនៃការវិភាគនេះ គឺដើម្បីបានយល់ដឹងថែមទៀតពីដំណើរការ

វិមជ្ឈការ និងផ្តល់ជាអនុសាសន៍ជាទូទៅដើម្បីជំរុញអោយកាន់តែប្រសើរនូវដំណើរការវិមជ្ឈការនៅកម្ពុជា។

## ១_ ការប្រមូលទិន្នន័យ

ដោយសារការវាយតំលៃនេះ ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការយល់ដឹងរបស់ពលរដ្ឋអំពីវិមជ្ឈការ ក្រុមស្រាវជ្រាវបានធ្វើការស្រង់ទិន្នន័យតាមការសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាឃុំ_សង្កាត់ចំនួន៩សង្កាត់នៅក្នុងក្រុងភ្នំពេញ និង១៨ឃុំនៅតាមខេត្ត។ ជាមួយគ្នានោះដែរ ក្រុមស្រាវជ្រាវបានសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សា ច្រើននាក់ក្នុងឃុំ_សង្កាត់នីមួយៗ ដើម្បីអោយពួកគេអាចបង្ហាញនូវទស្សនះអំពីការងារក្រុមប្រឹក្សាឃុំសង្កាត់។ នៅក្នុងគោលគំនិតនេះ វិទ្យាស្ថានបានជូនជាសំនួរសម្ភាសន៍ដល់សមាជិកក្រុមប្រឹក្សា ៣នាក់ នៅក្នុងឃុំ_សង្កាត់នីមួយៗ បន្ថែមលើការសម្ភាសន៍ជាមួយមេឃុំ_ចៅសង្កាត់។ ជាសរុប វិទ្យាស្ថានបានសំនួរទាំងអស់ចំនួន៦៨ ពីសមាជិកក្រុមប្រឹក្សាឃុំ_សង្កាត់។ វិទ្យាស្ថានក៏ធ្វើការស្តាប់ស្ទង់មតិជាមួយនឹងសាធារណជនចំនួន២៧១នាក់ នៅខេត្តតាកែវ កំពត និងភ្នំពេញ អំពីការយល់ដឹងរបស់គាត់អំពីសកម្មភាពក្រុមប្រឹក្សាឃុំ_សង្កាត់។ ការវាយតំលៃនៅក្នុងខណៈនោះ ទទួលបានទិន្នន័យទាំងបរិមាណ និងគុណភាពតាមដែលអាចធ្វើទៅបាន នៅចំពេលដែលក្រុមប្រឹក្សាឃុំ_សង្កាត់ ក៏ដូចជាប្រជាពលរដ្ឋមានការមមាញឹកជាប់រវល់។ យល់ព្រមតាមសំណូមពររបស់អ្នកចូលរួម ក្រុមស្រាវជ្រាវមិនបានបញ្ជាក់អំពីអត្តសញ្ញាណអ្នកសម្ភាសន៍ទេ ដោយបានដាក់លេខជំនួសវិញ។

## ២_ កិច្ចសម្ភាសន៍ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ_សង្កាត់

ក្នុងកិច្ចសម្ភាសន៍ជាមួយសង្កាត់ចំនួន៩នៅក្រុងភ្នំពេញ ក្រុមស្រាវជ្រាវបានធ្វើការសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ចំនួន២នាក់ ដោយសារតែចៅសង្កាត់ជាប់រវល់។ នៅក្នុងការសម្ភាសន៍នៅទីក្រុងភ្នំពេញនេះ មានស្ត្រី២នាក់ ហើយម្នាក់មានឋានះជាចៅសង្កាត់។

នៅក្នុងការស្នើសុំធ្វើការសម្ភាសន៍ នៅតាមខេត្ត វិទ្យាស្ថានមិនបានបញ្ជាក់ថានរណាទេ គ្រាន់តែសុំសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ។ នៅពេលជួបសម្ភាសន៍ ក្រុមការងារបានជួបនឹងឥស្សរៈជននៃជីវភាពនយោបាយនៅជនបទៈ សមាជិកក្រុមប្រឹក្សាឃុំទាំងនោះសុទ្ធតែជាបុរស និងជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា។ មានតែឃុំចំនួន២ប៉ុណ្ណោះ ដែលក្រុមការងារបានជួបជាមួយជំទប់ទីមួយ និងជំទប់ទី២ (ឃុំ៦) និងសមាជិកក្រុមប្រឹក្សាឃុំ (ឃុំ១៥)។ ក្នុងឃុំផ្សេងទៀត វិទ្យាស្ថានបានសម្ភាសន៍ជាមួយប្រធានក្រុមប្រឹក្សាឃុំ ដែលមានសមាជិកក្រុមប្រឹក្សាឃុំចូលរួមតែមិនមានមតិទេ។

## ៣_ សំនួរចំពោះសមាជិកក្រុមប្រឹក្សាឃុំ

នៅពេលបញ្ចប់ការសម្ភាសន៍ វិទ្យាស្ថានបានចែកសំនួរដល់សមាជិកក្រុមប្រឹក្សា៣នាក់ឱ្យបំពេញតាមឃុំ សរុបទាំងអស់ចំនួន៦៨នាក់។ សមាជិកក្រុមប្រឹក្សាឃុំភាគច្រើន ជាសមាជិកគណបក្សប្រជាជនកម្ពុជា ប្រហែល៨%ជាសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិច និងប្រហែល១៦% មកពីគណបក្សសមរង្ស៊ី។

| ភេទ | ចំនួន | ភាគរយ |
|---|---|---|
| ប្រុស | ៥៥ | ៨០.៩០ |
| ស្រី | ៦ | ៨.៨០ |
| សរុប | ៦១ | ៨៩.៧០ |
| អវត្តមាន | ៧ | ១០.៣០ |
| សរុបទាំងអស់ | ៦៨ | ១០០.00 |

តារាងទីមួយៈភេទ

ស្ត្រីសមាជិកក្រុមប្រឹក្សាឃុំ មានតែ៦នាក់ ប៉ុណ្ណោះដែលបានបំពេញសំនួរ ។ បង្ហាញថា មានស្ត្រីតិចតួចណាស់ បានចូលរួមក្នុងនយោបាយមូលដ្ឋាន។

| គណបក្ស | ចំនួន | ភាគរយ |
|---|---|---|
| ហ្វ៊ុនស៊ិនប៉ិច | ៥ | ៧.៤០ |
| ប្រជាជន | ៤៨ | ៧០.៦០ |
| សមរង្ស៊ី | ១០ | ១៤.៧០ |
| សរុប | ៦៣ | ៩២.៦០ |
| អវត្តមាន | ៥ | ៧.៤០ |
| សរុបទាំងអស់ | ៦៨ | ១០០.00 |

តារាងទីពីរ:គណបក្ស

## ៤_ សំនួរចំពោះប្រជាពលរដ្ឋ

ព្រមជាមួយនឹងកិច្ចសម្ភាសន៍ មន្ត្រីកម្មវិធីរបស់វិទ្យាស្ថាន បានចែកជាសំនួរ ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ_សង្កាត់ ដោយមានការសហការផងដែរ ពីដៃគូរបស់វិទ្យាស្ថាននៅតាមខេត្ត។ ពលរដ្ឋសរុបចំនួន២៧១នាក់ បានបំពេញសំនួរ ក្នុងនោះខេត្តកំពត៩១នាក់ ខេត្តតាកែវ៩០នាក់ និងក្រុងភ្នំពេញ៩០នាក់ មានបុរស១៥២នាក់ និងស្ត្រី ១០៥នាក់។

| ភេទ | ចំនួន | ភាគរយ |
|---|---|---|
| ប្រុស | ១៥២ | ៥៦.១០ |
| ស្រី | ១០៥ | ៣៨.៧០ |
| សរុប | ២៥៧ | ៩៤.៨០ |
| អវត្តមាន | ១៤ | ៥.២០ |
| សរុបទាំងអស់ | ២៧១ | ១០០.00 |

តារាងទីបី:ភេទ

# តួនាទី ភារកិច្ច និង ការទទួលខុសត្រូវ

គោលបំណងនៃការសម្ភាសន៍នេះ គឺចង់ស្វែងយល់ពីការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ពីភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ ក្រុមស្រាវជ្រាវមានការចាប់អារម្មណ៍ជាពិសេស ពីការយល់ឃើញរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ពីភារកិច្ចរបស់គេ និងអំពីវិមជ្ឈការ។ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ភាគច្រើន បានមានប្រសាសន៍ថា ក្រុមប្រឹក្សាមានភារកិច្ចធំពីរដែលត្រូវបំពេញ: ទីមួយគឺតំណាងអោយពលរដ្ឋក្នុងឃុំ-សង្កាត់ ទីពីរគឺធ្វើជាភ្នាក់ងាររបស់រដ្ឋ (ឧទាហរណ៍ អនុវត្តន៍ការងាររដ្ឋដូចជាចុះឈ្មោះអ្នកបោះឆ្នោត)។ នេះជាភារកិច្ចដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មួយចំនួន បានលើកឧទាហរណ៍ជាក់ស្តែងអំពី ការងាររបស់គាត់។ ឧ. សមាជិកក្រុមប្រឹក្សាក្នុងឃុំ២ បានពន្យល់ថាការងារដែល សំខាន់បំផុតរបស់ក្រុមប្រឹក្សា គឺអភិវឌ្ឍន៍សហគមន៍។ នៅឃុំ-សង្កាត់មួយចំនួនទៀត សមាជិកក្រុមប្រឹក្សាមានភារកិច្ចផ្សេងៗគ្នា។ ក្នុងឃុំ៥បាននិយាយថាការ ងាររបស់មេឃុំ គឺត្រូវធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។ មេឃុំនិងចៅសង្កាត់១៤ បាននិយាយថា ការងាររបស់គាត់គឺត្រូវដឹកនាំប្រជាពលរដ្ឋនៅក្នុងឃុំ។ គំនិតទាំងនេះបង្ហាញពីការយល់ដឹងផ្ទាល់ខ្លួនរបស់ក្រុមប្រឹក្សាអំពីវិមជ្ឈការ នៅពេលដែលក្រុមប្រឹក្សាបានបែងចែកភារកិច្ចខុសៗគ្នាតាមឃុំដែលវិទ្យាស្ថានបានធ្វើការសម្ភាសន៍។ វិទ្យាស្ថានសង្កេតឃើញថា ការលើកឡើងពីភារកិច្ចនេះវាផ្ទុយនឹងភារកិច្ចដែលមានចែងស្តីពីការបំរើប្រជាជន និងធ្វើជាតំណាងរបស់រដ្ឋ។

# សមត្ថភាពក្នុងការអនុវត្តវិមជ្ឈការ

ផ្នែកនេះគឺផ្តោតលើការយល់ដឹង របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងបញ្ញត្តិច្បាប់ អំពីគោលនយោបាយវិមជ្ឈការ ដូចមានចែងនៅក្នុង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ខែមីនា ឆ្នាំ២០០១។ ការស្រាវជ្រាវនឹងផ្តោតផងដែរ ទៅលើភាពប្រឈមសេចក្តីត្រូវការផ្នែកបណ្តុះបណ្តាល និងលទ្ធភាពហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាក្នុងការអនុវត្ត បទបញ្ញត្តិនានា។ លទ្ធផលបានបង្ហាញពីកំរិតខុសគ្នានៃការយល់ដឹងរបស់ក្រុមប្រឹក្សានៅ ខេត្ត និងទីក្រុងអំពីក្របខណ្ឌច្បាប់។

## ១- ការយល់ដឹងអំពីវិមជ្ឈការ

តាមការសម្ភាសន៍ សមាជិកក្រុមប្រឹក្សានៅភ្នំពេញមានការយល់ដឹងច្បាស់អំពីក្របខណ្ឌច្បាប់ ក៏ដូចជាតួនាទី និងភារកិច្ច។ ភាគច្រើននៃសមាជិកក្រុមប្រឹក្សាអាចពន្យល់ពីភារកិច្ចចំបងរបស់សង្កាត់ សមស្របទៅនឹងខ្លឹមសារដែលមានចែងនៅក្នុងក្របខណ្ឌច្បាប់ (ដូចជាធ្វើជាភ្នាក់ងាររបស់រដ្ឋ និងបំរើប្រជាពលរដ្ឋ)។ ភាគច្រើនការរៀបរាប់របស់សមាជិកក្រុមប្រឹក្សាមានភាពត្រឹមត្រូវនឹងភារកិច្ច ដែលមានចែងនៅក្នុងច្បាប់។

នៅតាមខេត្តសមាជិកក្រុមប្រឹក្សាមួយចំនួនធំបាននិយាយថា គាត់អាចយល់បានពីក្របខណ្ឌច្បាប់។
ប៉ុន្តែនៅពេលដែលសួរថាមានការពិបាកទេនៅក្នុងការអនុវត្តបទបញ្ញត្តិនានារបស់រដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាភាគច្រើនឆ្លើយថាគាត់មានការលំបាក ហើយមិនយល់ថាក្របខណ្ឌច្បាប់ជាអ្វី។ ទោះបីជាសមាជិកក្រុមប្រឹក្សាភាគច្រើនបានចូលរួមក្នុងនយោបាយមូលដ្ឋានអស់រយៈពេលច្រើនឆ្នាំមុនអាណត្តិប្រាំឆ្នាំជាក្រុមប្រឹក្សាក៏ដោយ (ឧ.ធ្វើ

ជាមេភូមិ)

ភាគច្រើនមិនដឹងថាអនុវត្តនយោបាយវិមជ្ឈការក្នុងក្របខណ្ឌច្បាប់ដោយរបៀបណាឡើយ។ នេះអាចបង្ហាញថាបទពិសោធន៍ក្នុងតំណែងនានា ទាក់ទងនឹងការគ្រប់គ្រងឃុំ មិនប្រាកដថាអាចបំពេញការងារជាក្រុមប្រឹក្សាឃុំបានទេ។

ទាក់ទិននឹងចំនុចនេះ សមាជិកក្រុមប្រឹក្សាភាគច្រើនបាននិយាយថា គាត់មានការលំបាកក្នុងការអនុវត្តក្របខណ្ឌច្បាប់ ដោយសារថាវិមជ្ឈការជាគោលនយោបាយថ្មី ដែលទាមទារនូវរយៈពេលមួយ សំរាប់ឱ្យក្រុមប្រឹក្សាបានយល់។ ចៅសង្កាត់លេខ៨បានប្រៀបធៀបសភាពការណ៍ដូចជា "ក្មេងដែលកំពុងរៀនដើរ" (កិច្ចសម្ភាសន៍ទី៩)។ សមាជិកក្រុមប្រឹក្សាក្នុងឃុំលេខ១១ និងឃុំលេខ៩បាននិយាយថា ទោះបីជាពិបាកយល់ពីក្របខណ្ឌច្បាប់ក៏ដោយ ក៏សមាជិកក្រុមប្រឹក្សាមានការវិវឌ្ឍន៍ដែរ ដោយសារមានការបណ្តុះបណ្តាល និងបទពិសោធន៍ជាក់ស្តែង។ នេះជាចំណុចវិជ្ជមានមួយ បើប្រៀបធៀបទៅនឹងការលំបាក ដែលសមាជិកក្រុមប្រឹក្សាបានជួបប្រទះ ដោយសារការអនុវត្តន៍វិមជ្ឈការនៅក្មេងខ្ចី។ ជាចំណុចវិជ្ជមានមួយទៀតដែរ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់មិនអស់សង្ឃឹមចំពោះភាពប្រឈមមុខទាំងឡាយ ហើយបានចាត់ទុកថាជាការរៀនសូត្រមួយ ដែលនៅទីបញ្ចប់អាចយល់ដឹង និងអនុវត្តន៍វិមជ្ឈការបាន។ សមាជិកក្រុមប្រឹក្សាលេខ ២ បានពន្យល់ថា "យើងរៀនផងធ្វើការផង"។

ធនធានមួយចំនួនអាចបាត់បង់នៅក្នុងការបោះឆ្នោតខាងមុខ ដោយសារថានឹងមានសមាជិកក្រុមប្រឹក្សាថ្មី ដែលត្រូវរៀនសូត្រពីដំណើរការនេះជាថ្មីឡើងវិញ។

វ័យចាស់ជរាក៏ជាបញ្ហាប្រឈមមុខមួយដែរ។ សមាជិកក្រុមប្រឹក្សាមួយចំនួនមានអាយុជាង៧០ឆ្នាំបាននិយាយថា គាត់មិនសូវយល់ពីក្របខណ្ឌច្បាប់ និងចងចាំខ្លឹមសារនៃវគ្គបណ្តុះបណ្តាលទេ។
សមាជិកក្រុមប្រឹក្សាដែលមានវ័យចាស់នៅឃុំ១៨មានប្រសាសន៍ ថា

"គាត់មិនសូវយល់ថាអ្វីជាវិមជ្ឈការនោះទេ"។ ទោះបីជាយ៉ាងណាក៏ដោយសមាជិកក្រុមប្រឹក្សាទាំងនោះ មានបំណងនឹងឈរឈ្មោះជាក្រុមប្រឹក្សាម្តងទៀតនៅពេលបោះឆ្នោតនាខែមេសា២០០៧។ វិទ្យាស្ថានយល់ឃើញថា គួរពិនិត្យពិចារណាអំពីតំរូវការជាពិសេសរបស់សមាជិកក្រុមប្រឹក្សាចាស់ៗទាំងនោះ នៅពេលរៀបចំវគ្គបណ្តុះបណ្តាលព្រោះអាចមានសមាជិកក្រុមប្រឹក្សាវ័យចាស់ច្រើននៅក្នុងអាណត្តិទី២។

មានតែសមាជិកក្រុមប្រឹក្សាក្នុងឃុំចំនួន៥ទេ ដែលនិយាយថាឃុំគាត់មិនពិបាកយល់ក្របខណ្ឌច្បាប់ទេ ដោយសារគាត់មានសៀវភៅមួយ ដែលពន្យល់អំពីទិដ្ឋភាពនានានៃវិមជ្ឈការ ហើយបានផ្តល់ឱ្យដោយអង្គការក្រៅរដ្ឋាភិបាលមួយ។ គាត់នឹងទាក់ទងជាមួយគ្រូបណ្តុះបណ្តាលបើសៀវភៅនោះមិនមានព័ត៌មានគ្រប់គ្រាន់។ ការផ្តល់សៀវភៅពីក្របខណ្ឌច្បាប់ដល់ក្រុមប្រឹក្សា និងការផ្តល់មតិយោបល់ពីការអនុវត្តវិមជ្ឈការអាចដោះ ស្រាយបញ្ហាប្រឈមមួយចំនួន។ សមាជិកក្រុមប្រឹក្សាមិនគួរពឹងផ្អែកទាំងស្រុងលើវគ្គ បណ្តុះបណ្តាលទេ ជាពិសេសនៅពេលដែលគាត់មិនមានពេលគ្រប់គ្រាន់ក្នុងការចូលរួម វគ្គបណ្តុះបណ្តាល និងបំពេញកិច្ចការប្រចាំថ្ងៃ។ សមាជិកក្រុមប្រឹក្សាអាចសិក្សាស្រាវជ្រាវនៅក្នុងសៀវភៅឯកសារ នូវចំណុចណាមួយដែលមិនមាននៅក្នុងវគ្គបណ្តុះបណ្តាលហើយយល់មិនសព្វជ្រុងជ្រោយ។

## ២_ វគ្គបណ្តុះបណ្តាល

ពាក់ព័ន្ធទៅនឹងការយល់ដឹងពីក្របខណ្ឌច្បាប់ ក្រុមស្រាវជ្រាវបានសាកសួរក្រុមប្រឹក្សា ពីការបណ្តុះបណ្តាលស្តីពីវិមជ្ឈការ។ ក្រុមប្រឹក្សាបានទទួលការបណ្តុះបណ្តាលពីក្រសួងមហាផ្ទៃស្តីអំពីការអនុវត្តក្របខណ្ឌច្បាប់ និងការគ្រប់គ្រងរដ្ឋបាលឃុំ_សង្កាត់។ ក្រុមប្រឹក្សាក៏បានទទួលការបណ្តុះបណ្តាលផងដែរ ពីក្រសួងផ្សេងៗទៀតលើប្រធានបទ

ជាក់លាក់ ដូចជាអំពើហិង្សាក្នុងគ្រួសារ (ឃុំ១១) ឬពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ។ ចៅសង្កាត់លេខ៣បានមានប្រសាសន៍ថា ការបណ្តុះបណ្តាលរៀបចំដោយ ក្រសួងមិនទទួលបានជោគជ័យទេ ដោយសារថាក្រុមប្រឹក្សាមិនយល់ពីខ្លឹមសារនៃមេរៀន។ មេឃុំវ័យចាស់ៗមួយចំនួនមិនបានចាំប្រធានបទ ដែលបានរៀននោះទេ (កិច្ចសម្ភាសន៍ឃុំចំនួន១៥)។ ភាគច្រើននៃក្រុមប្រឹក្សាឃុំវ័យចំណាស់យល់ឃើញថា វគ្គបណ្តុះបណ្តាលមិនស្របតាមតំរូវការ និងជំនាញរបស់គាត់ទេ: "យើងមានវ័យចាស់ដូចនេះមានការលំបាកក្នុងការចងចាំអ្វីដែលយើងបានរៀន" (កិច្ចសម្ភាសន៍ឃុំលេខ១២)។ វិទ្យាស្ថានយល់ឃើញថា គួររៀបចំវគ្គបណ្តុះបណ្តាលទៅតាមតំរូវការរបស់ក្រុមប្រឹក្សា។ តាមចៅសង្កាត់លេខ៤ វគ្គបណ្តុះបណ្តាលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាល មានលក្ខណះជាក់លាក់ (ដូចជាអំពីអំពើហិង្សា ឬយែនឌ័រ) ជាងវគ្គបណ្តុះបណ្តាលរបស់រដ្ឋាភិបាល ដែលផ្តោតលើប្រធានបទជាទូទៅ ដូចជាច្បាប់គ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សា ឃុំ-សង្កាត់។

ក្រុមប្រឹក្សាបានលើកឡើង ពីសេចក្តីត្រូវការបណ្តុះបណ្តាលបន្ថែមទៀត។ ក្រុមប្រឹក្សាឃើញថា វគ្គបណ្តុះបណ្តាលទទួលបានកន្លងមកមានសារះសំខាន់ណាស់ តែមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ក្រុមប្រឹក្សាសង្កាត់មានសំណូមពរឱ្យផ្តោតការបណ្តុះបណ្តាលពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ការធ្វើផែនការអភិវឌ្ឍន៍ និងការគ្រប់គ្រងហិរញ្ញវត្ថុ (កិច្ចសម្ភាសន៍៤)។ ក្រុមប្រឹក្សាបាននិយាយថា គាត់មិនបានទទួលការបណ្តុះបណ្តាលពីច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណីទេ គាត់គិតថានេះជាការចាំបាច់សំរាប់ការបំពេញការងារជាពិសេសនៅក្នុងក្របខ័ណ្ឌនៃដំណោះស្រាយជំលោះក្រៅប្រព័ន្ធតុលាការ (កិច្ចសម្ភាសន៍១២)។ មានតែក្រុមប្រឹក្សាក្នុងឃុំលេខ១១ ដែលថាមិនត្រូវការការបណ្តុះបណ្តាលបន្ថែមទៀតទេ។

ចៅសង្កាត់លេខ២ចង់អោយបណ្តុះបណ្តាលពីការធ្វើផែនការអភិវឌ្ឍន៍ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា ដូចមានចែងក្នុងក្របខណ្ឌច្បាប់។ ចៅសង្កាត់ជាច្រើនចង់បានការបណ្តុះបណ្តាលអំពីការស្នើសុំជំនួយបន្ថែមពីរដ្ឋាភិបាល និងអង្គការនានា (កិច្ចសម្ភាសន៍៣)។ ចៅសង្កាត់លេខ៩ បានទទួលប្រភពធនធានតែពីរដ្ឋាភិបាល ចង់ឱ្យអង្គការក្រៅរដ្ឋាភិបាលបណ្តុះបណ្តាលពីរបៀបស្នើសុំជំនួយ។ ក្រុមប្រឹក្សាចង់ឱ្យមានការបណ្តុះបណ្តាលទូទៅផង (ក្របខណ្ឌច្បាប់ និងការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់) និងលើប្រធានបទជាក់លាក់ផង (ការធ្វើផែនការអភិវឌ្ឍន៍ ការស្នើសុំជំនួយ)។ ក្រុមប្រឹក្សាមួយចំនួនបានគូសបញ្ជាក់ថា ការចូលរួមវគ្គបណ្តុះបណ្តាលបានធ្វើឱ្យក្រុមប្រឹក្សាមិនបានបំពេញភារកិច្ចប្រចាំថ្ងៃ។ ជាដំណោះស្រាយ ចៅសង្កាត់លេខ៤ បានផ្តល់អនុសាសន៍ឱ្យរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឧ. មួយថ្ងៃក្នុងមួយខែ និងត្រូវគិតថា ក្រុមប្រឹក្សាត្រូវបំពេញការងារប្រចាំថ្ងៃផងដែរ។

ភាគច្រើននៃក្រុមប្រឹក្សាឃុំបានទទួលការបណ្តុះបណ្តាលពីទំនាស់ដីធ្លី ដែលជាបញ្ហាស្រួចស្រាវនៅក្នុងប្រទេសកម្ពុជា។ សមាជិកក្រុមប្រឹក្សាម្នាក់បានធ្វើទស្សនះកិច្ចឃុំគំរូមួយក្នុងខេត្តកំពង់ចាម រៀបចំដោយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ហើយចាត់ទុកថាជាបទពិសោធន៍ល្អ (កិច្ចសម្ភាសន៍៣)។ ការរៀបចំទស្សនះកិច្ចសិក្សាសំរាប់សមាជិកក្រុមប្រឹក្សាអាចជា បទពិសោជន៍ដ៏មានតំលៃ ព្រោះក្រុមប្រឹក្សាអាចយល់ពីការអនុវត្តវិមជ្ឈការដោយជោគជ័យ។ ការធ្វើទស្សនកិច្ចសិក្សានិងការអនុវត្តជាក់ស្តែងអាចជួយបំពេញការអនុវត្តទ្រឹស្តី (ឧ.ក្របខណ្ឌច្បាប់) នៅក្នុងឃុំរបស់គាត់។

ក្រុមប្រឹក្សាផ្តល់យោបល់ថា គួរមានការបណ្តុះបណ្តាល ឬផ្សព្វផ្សាយផងដែរពីដំណើរការនៃការងាររបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាសង្កាត់ឃើញប្រជាពលរដ្ឋ មិនចាប់អារម្មណ៍នឹងការងាររបស់ឃុំ ដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើគំរោងអភិវឌ្ឍន៍ និងកិច្ចការដ៏ទៃទៀតរបស់ឃុំ។ ការអប់រំប្រជាពលរដ្ឋអាចជាការងារធំធេងសំរាប់អង្គការមិនមែនរដ្ឋា

ភិបាល ឬរដ្ឋាភិបាល តែគួរមានការបណ្តុះបណ្តាលក្រុមប្រឹក្សាឱ្យចេះពន្យល់អប់រំប្រជាពលរដ្ឋអំពីសារៈសំខាន់នៃវិមជ្ឈការ ការចូលរួមក្នុងវិមជ្ឈការ និងការជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួម។

## ៣_ អនុសាសន៍សំរាប់ការបណ្តុះបណ្តាលនាពេលអនាគត

ផ្អែកលើបទពិសោធន៍របស់ក្រុមប្រឹក្សាពីការបណ្តុះបណ្តាល វិទ្យាស្ថានសូមលើកជាអនុសាសន៍សំរាប់ការបណ្តុះបណ្តាលក្រុមប្រឹក្សានាពេលអនាគត។

### សេចក្តីត្រូវការរបស់ក្រុមប្រឹក្សា

ការបណ្តុះបណ្តាលចាំបាច់តម្រូវទៅតាមសេចក្តីត្រូវការជាពិសេស របស់ក្រុមប្រឹក្សាបើសិនជាអាចធ្វើទៅបាន។ អាយុច្រើន និងកំរិតវប្បធ៌មទាបអាចធ្វើឱ្យក្រុមប្រឹក្សាពិបាកយល់ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល។ នៅពេលដែលអាយុ និងកំរិតវប្បធ៌មមិនស្មើ គ្នា គ្រូបង្គោលគួរយកចិត្តទុកដាក់ជាពិសេសចំពោះសមាជិកក្រុមប្រឹក្សាណាដែលមាន ការលំបាកក្នុងការតាមមេរៀន។ គួរពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអំពីខ្លឹមសារ និង ប្រធានបទនៃមេរៀន។

### ការបណ្តុះបណ្តាលជាលក្ខណៈអន្តរសកម្ម

ជាទូទៅ

វគ្គបណ្តុះបណ្តាលមានប្រសិទ្ធភាពលុះណាមានលក្ខណៈអន្តរសកម្មរវាង គ្រូនិងសិស្ស ដើម្បីឱ្យវគ្គបណ្តុះបណ្តាលមានលក្ខណៈទាក់ទាញអារម្មណ៍។ កត្តាចំបងគឺគ្រូបង្គោលត្រូវមានទេពកោសល្យនិងគរុកោសល្យក្នុងការបង្រៀន។

### ការបណ្តុះបណ្តាលដល់ក្រុមផ្សេងទៀត

ក្រុមប្រឹក្សាបានយល់ថា វិមជ្ឈការមិនត្រឹមតែជាភារកិច្ចរបស់គាត់ដែលជាអ្នកតំណាងឱ្យប្រជាពលរដ្ឋដែលបានបោះឆ្នោតឱ្យប៉ុណ្ណោះទេ ពួកគាត់ក៏មានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំផងដែរ។ ក្រុមប្រឹក្សាបានចាត់ទុកថាការសហការណ៍របស់ប្រជាពលរដ្ឋ និងមេភូមិជាការចាំបាច់ណាស់ក្នុងការបំពេញការងាររបស់ក្រុមប្រឹក្សា។ ដោយសារម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនពុំមានលទ្ធភាពក្នុងការបណ្តុះបណ្តាលពួកគាត់ ដូចនេះ គួរមានប្រធានបទមួយស្តីអំពីវិធីសាស្ត្រនៅក្នុងការជំរុញឱ្យមានការចូលរួម នៅក្នុងគំរោងនៃការបណ្តុះបណ្តាលក្រុមប្រឹក្សានាពេលខាងមុខ។

### យែនឌ័រ

ចំនួនដ៏តិចតួចនៃក្រុមប្រឹក្សាជាស្ត្រីនៅក្នុងឃុំ បង្ហាញពីតំរូវការនៃការបណ្តុះបណ្តាលអំពីសិទ្ធិស្ត្រី និងលទ្ធិប្រជាធិបតេយ្យដែលមិនត្រឹមតែផ្តល់ចំនេះដឹងពីវិមជ្ឈការប៉ុណ្ណោះទេ តែថែមទាំងផ្តល់ជំនឿទុកចិត្តដល់ស្ត្រី អំពីសិទ្ធិនិងលទ្ធភាពរបស់គាត់ក្នុងការបំពេញការងារ។ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ បានរៀបចំជាវគ្គបណ្តុះបណ្តាលជាច្រើន ដើម្បីជុំរុញស្ត្រីឱ្យចូលរួមក្នុងការងារនយោបាយ។ វិទ្យាស្ថានមានគំរោងនឹងបន្តការបណ្តុះបណ្តាលនេះ ដល់ស្ត្រីដែលជាប់ឆ្នោតថ្មី នាការបោះឆ្នោតខែមេសាឆ្នាំ២០០៧។ ស្ត្រីក្រុមប្រឹក្សាត្រូវការពង្រឹងសមត្ថភាព ទើបអាចបំពេញការងារជាមួយក្រុមប្រឹក្សាឃុំបុរសបាន។

### ឃុំគំរូ

ការធ្វើទស្សនៈកិច្ចឃុំគំរូ អាចធ្វើឱ្យមានការឆាប់យល់ការអនុវត្តជាក់ស្តែង នូវនយោបាយវិមជ្ឈការ ជាពិសេសចំពោះក្រុមប្រឹក្សាដែលមានកំរិតវប្បធ៌មទាប និងវ័យ

ចាស់។ ក្រុមប្រឹក្សានឹងចងចាំពីអ្វីដែលបានទស្សនា របៀបនៃការគ្រប់គ្រងឃុំនិងធនធាន នឹងធ្វើឱ្យគាត់មានគំនិតផ្ដួចផ្ដើមសំរាប់ការអភិវឌ្ឍឃុំរបស់គាត់។

**ហិរញ្ញវត្ថុ**

បើពិនិត្យមើលពីថវិកាដ៏ស្ដួចស្ដើងដែលក្រុមប្រឹក្សាបានទទួលពីរដ្ឋាភិបាល គួរមានការបណ្ដុះបណ្ដាលពីការគ្រប់គ្រងធនធានហិរញ្ញវត្ថុឱ្យបានល្អ និងពីរបៀបនៃការស្វះស្វែងរកធនធានបន្ថែមទៀត។ ក្រុមប្រឹក្សាក៏ត្រូវយល់ផងដែរ ពីសារៈសំខាន់នៃការប្រាប់ប្រជាពលរដ្ឋអំពីធនធានថវិកាដែលឃុំមានដើម្បីឱ្យមានតម្លាភាព និងជៀសវាងនូវការខកចិត្តរបស់ប្រជាពលរដ្ឋចំពោះអ្វីដែលបានរំពឹងទុកចំពោះការងាររបស់ក្រុមប្រឹក្សា។ បន្ថែមលើនេះ ក្រុមប្រឹក្សាត្រូវបញ្ជាក់ពីគោលបំណងនៃការប្រមូលទុនចូលរួមពីម្ចាស់ជំនួយ និងប្រជាពលរដ្ឋឱ្យគាត់បានយល់។

**ការដោះស្រាយជម្លោះ**

ក្រុមប្រឹក្សាគួរមានការបណ្ដុះបណ្ដាលពីច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណីក៏ដូចជាបញ្ហាដំណោះស្រាយដីធ្លី អំពើហឹង្សាក្នុងគ្រួសារ និងសហការជាមួយទីប្រឹក្សាពលរដ្ឋរបស់វិទ្យាស្ថានដែលផ្ដល់ការប្រឹក្សាយោបល់លើផ្នែកច្បាប់ដល់ប្រជាពលរដ្ឋ។

**ការចូលរួមរបស់ប្រជាពលរដ្ឋ**

គួរបណ្ដុះបណ្ដាលក្រុមប្រឹក្សា ពីរបៀបដោះស្រាយតំរូវការរបស់ប្រជាពលរដ្ឋសិទ្ធិ ជាមូលដ្ឋានរបស់ពលរដ្ឋ សារៈសំខាន់នៃការចូលរួមរបស់ពលរដ្ឋនៅក្នុងការងារក្រុមប្រឹក្សា និងការបញ្ចុះបញ្ចូលឱ្យមានការចូលរួម។

**ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម**

ទិសដៅនៃការបណ្តុះបណ្តាល គួរផ្តោតលើការពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សាឱ្យត្រៀមលក្ខណៈចំពោះភារកិច្ច និងភាពប្រឈមទាំងឡាយនាពេលអនាគត។ នៅក្នុងអាណត្តិទីមួយនេះ មានការផ្តួចផ្តើមគំនិតល្អនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រចាំឆ្នាំប៉ុន្តែផែនការរបស់ឃុំនៅមានកំរិតនៅឡើយ។ នាពេលអនាគតគួរសំរេចឱ្យបាននូវគំរោងធំៗ ជាអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋដោយរួមបញ្ចូលនូវគំរោងថែទាំសុខភាពសាលារៀន។ល។

## ៤. ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាទទួលបានធនធានមកពីប្រភពបីជាចំបងៈ រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអំណោយឯកជន (តារាងទី៩) និងទុនចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ក្រុមប្រឹក្សាបានទទួលប្រភពធនធានពីរដ្ឋាភិបាល ប៉ុន្តែមិនគ្រប់គ្រាន់ទេដើម្បីឱ្យក្រុមប្រឹក្សាអនុវត្តភារកិច្ច និងគំរោងផែនការអភិវឌ្ឍន៍។ នៅក្នុងទីក្រុងភ្នំពេញ សង្កាត់ភាគច្រើន ទទួលបានជំនួយឧបត្ថម្ភបន្ថែម ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិនៅក្នុងគំរោងអភិវឌ្ឍន៍នានា។ នេះបង្ហាញឱ្យឃើញថា របនាសម្ព័ន្ធរដ្ឋបាលមូល

ដ្ឋាន អាចជាយន្តការមួយសំរាប់ទទួលជំនួយសំរាប់គំរោងអភិវឌ្ឍន៍សហគមន៍។ ជាសញ្ញាវិជ្ជមានមួយ និងជាការរៀបចំបានល្អដើម្បីឱ្យមាននិរន្តភាព និងភាពស្របច្បាប់របស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាភាគច្រើនមានសំណូមពរឱ្យ មានការបណ្តុះបណ្តាលពីរបៀបនៃការស្នើសុំជំនួយ ដែលអាចឱ្យក្រុមប្រឹក្សាមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ។

ក្រុមប្រឹក្សានិយាយថា ធនធានដែលផ្តល់ដោយរដ្ឋាភិបាល មិនគ្រប់គ្រាន់ទេដើម្បី

បំពេញភារកិច្ចរបស់គេ។ ឃុំរបស់គាត់អាច

អនុវត្តន៍គំរោងមួយចំនួនប៉ុណ្ណោះ នៃផែនការ អភិវឌ្ឍន៍ (៧៦.៦%) ឬមិនគ្រប់គ្រាន់សំរាប់ អនុវត្តន៍គំរោងឱ្យបានពេញលេញ (៧៣.៤%)។ ភាគច្រើននៃក្រុមប្រឹក្សាបាន ចាត់ទុកថាកង្វះ

| ឧបសគ្គនៃវិមជ្ឈការនៅកម្ពុជា | ចំលើយ | ភាគរយ |
|---|---|---|
| កង្វះធនធាន | ៦២ | ៩៦.៩០ |
| កង្វះការចូលរួមពីពលរដ្ឋ | ៣៩ | ៦០.៩០ |
| កង្វះការគាំទ្រពីរដ្ឋាភិបាល | ៣១ | ៤៨.៤០ |
| មូលហេតុផ្សេងៗទៀត | ១១ | ១៧.២០ |
| សរុប | ១៤៣ | |

តារាង៤: អ្វីជាឧបសគ្គដ៏ធំបំផុតចំពោះជោគជ័យនៃវិមជ្ឈការនៅកម្ពុជា?

ខាតធនធានជាបញ្ហាចំបងនៅក្នុងការបំពេញភារកិច្ចរបស់គាត់ និងអនុវត្តន៍គោលនយោបាយវិមជ្ឈការនៅកម្ពុជា (៩៦.៩%) (តារាង៤)។ សមាជិកក្រុមប្រឹក្សាស្ត្រីនៅសង្កាត់លេខ៥បានឱ្យដឹងថា សង្កាត់បានទទួលប្រាក់វិភាជន៍ពីរដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍គំរោងនានា តែមិនបានទទួលគ្រប់គ្រាន់ដើម្បីអនុវត្តន៍គំរោងធំៗទេ ដូចជាការពង្រីកផ្លូវឱ្យធំជាងមុន។ ជាហេតុធ្វើឱ្យក្រុមប្រឹក្សាផ្តោតលើគំរោងតូច (ហេដ្ឋារចនាសម្ព័ន្ធ)។

ប្រជាពលរដ្ឋរំពឹងទុកថា ក្រុមប្រឹក្សាមានគំរោងអភិវឌ្ឍន៍ជាច្រើននៅក្នុងឃុំ ឯចំណែកឃុំមិនមានធនធានសំរាប់ធ្វើ (កិច្ចសម្ភាសន៍៣ និង១២)។ ដូចនេះអាចធ្វើឱ្យប្រជាពលរដ្ឋមានការខកចិត្តចំពោះក្រុមប្រឹក្សា ហើយមិនចូលរួមក្នុងការងាររបស់ក្រុមប្រឹក្សាទៀតទេ។ បើពិនិត្យពីស្ថានភាពហិរញ្ញវត្ថុរបស់កម្ពុជា កង្វះខាតធនធានមិនអាចដោះស្រាយបាននាពេលអនាគតដ៏ខ្លីទេ។ ដូចនេះក្រុមប្រឹក្សាចាំបាច់ត្រូវរៀនពីរបៀបចាត់ចែងធនធានឱ្យមានប្រសិទ្ធភាពបំផុត។

មកដល់ពេលនេះ (ខែសីហា ២០០៦) ៣១%នៃក្រុមប្រឹក្សាទទួលបានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល (តារាង៥)។ នៅឃុំមួយចំនួន អង្គការមិនមែនរដ្ឋាភិបាលអនុវត្តន៍ដោយផ្ទាល់គំរោងរបស់គេ ដូចជាធ្វើការអប់រំអំពីទឹកស្អាត និងអនាម័យ (កិច្ចសម្ភាសន៍ទី៩)។ សមាជិកក្រុមប្រឹក្សាម្នាក់បានលើកឡើងថា

| អ្នកណាជាអ្នកផ្តល់ធនធានឱ្យក្រុមប្រឹក្សា? | ចំលើយ | ភាគរយ |
|---|---|---|
| រដ្ឋាភិបាល | ៦៥ | ៩៥.៩០ |
| អង្គការមិនមែនរដ្ឋាភិបាល | ២១ | ៣០.៩០ |
| កម្មវិធីស្បៀងអាហារពិភពលោក | ៥ | ៧.៤០ |
| ជំនួយឯកជន | ២៧ | ៣៩.៧០ |
| ប្រភពជំនួយផ្សេងៗ | ៧ | ១០.៣០ |
| សរុប | ១២៥ | |

តារាង៥: អ្នកណាជាអ្នកផ្តល់ធនធានឱ្យក្រុមប្រឹក្សា?

អង្គការមិនមែនរដ្ឋាភិបាលមិនចង់សហការជាមួយក្រុមប្រឹក្សាទេ: "អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន មិនទំនាក់ទំនងជាមួយយើងទេ ពីព្រោះយើងនៅតំបន់ជនបទដាច់ស្រយាល" (កិច្ចសម្ភាសន៍ទី៣)។ ការបណ្តុះបណ្តាលក្រុមប្រឹក្សាពីរបៀបទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីស្វែងរកដៃគូសំរាប់អភិវឌ្ឍន៍ មានអត្ថប្រយោជន៍សំរាប់ក្រុមប្រឹក្សា ព្រោះប្រាក់វិភាជផ្តល់ឱ្យដោយរដ្ឋាភិបាលមិនគ្រប់គ្រាន់ទេ។

សមាជិកក្រុមប្រឹក្សាយល់ឃើញថា ចាំបាច់ត្រូវប្រាប់ប្រជាពលរដ្ឋឱ្យដឹងពីការចំណាយរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាបានដឹងពីការចែងនៅក្នុងច្បាប់ពីការចូលរួមប្រាក់បដិភាគរបស់ប្រជាពលរដ្ឋនៅក្នុងគំរោងអភិវឌ្ឍន៍របស់ឃុំ។ ក្រុមប្រឹក្សាសង្កាត់បាននិយាយថា គាត់មិនមានបញ្ហាក្នុងការប្រមូលប្រាក់បដិភាគពីប្រជាពលរដ្ឋទេ ព្រោះប្រជាពលរដ្ឋបានចាត់ទុកគំរោងអភិវឌ្ឍន៍ទាំងនោះជារបស់ខ្លួន ហើយមានបំណងចូលរួមចំណែក ដើម្បីឱ្យមានជីវភាពរស់នៅកាន់តែប្រសើរ។ ក្រុមប្រឹក្សាឃុំ១៥មិនដែលបានប្រមូលវិភាគទានពីប្រជាពលរដ្ឋទេ ប៉ុន្តែមានគំរោងនឹងប្រមូលប្រាក់បដិភាគនៅពេលមានពិធីបុណ្យផ្សេងៗ។ ជាចំណុចមួយគួរឱ្យចាប់អារម្មណ៍ ដែលឃុំខ្លះអាចប្រមូលប្រាក់បដិភាគបាន (កិច្ចសម្ភាសន៍៥) ឯឃុំខ្លះទៀតមិនអាចធ្វើបាន (កិច្ចសម្ភាសន៍១៦)។ ក្រុមប្រឹក្សាឃុំ១៣បានពន្យល់ថា ប្រជាពលរដ្ឋមិនចង់ចូលរួមទេ បើគំរោងអភិវឌ្ឍន៍ធ្វើឡើងនៅភូមិផ្សេង (កិច្ចសម្ភាសន៍១៣)។

ក្រុមប្រឹក្សាយល់ថា ការប្រមូលប្រាក់បដិភាគមានសារៈសំខាន់ មិនចំពោះតែផ្នែកហិរញ្ញវត្ថុនោះទេ តែជាការកសាងផងដែរនូវភាពជាម្ចាស់ចំណែកនៃការអភិវឌ្ឍន៍នៅ

ក្នុងសហគមន៍: "បើសិនជាគាត់បានចូលរួមជាប្រាក់បដិភាគនោះគាត់នឹងជួយថែទាំផ្លូវ ព្រោះគាត់យល់ថាលុយរបស់គាត់ជាចំនែកមួយនៃផ្លូវនេះ" (កិច្ចសម្ភាសន៍៧)។ ក្រុមប្រឹក្សាមិនបានប្រាប់ពីចំនួនទឹកប្រាក់ដែលប្រមូលពីប្រជាពលរដ្ឋទេ តែក្រុមប្រឹក្សាខ្លះបានប្រាប់: ឃុំ៧យកមួយពាន់រៀលក្នុងមួយគ្រួសារ។ មានការចាត់ចែងខុសប្លែកពីគ្នានៅក្នុងការប្រមូលទុនចូលរួម។ នៅក្នុងឃុំលេខ១៧ ជាភារកិច្ចរបស់មេភូមិ ឯឃុំលេខ៧ ជាភារកិច្ចរបស់ គណៈកម្មការឃុំ។

បញ្ហាសំខាន់មួយ ដែលបានលើកឡើងទាក់ទងនឹងស្ថានភាពខ្វះខាតហិរញ្ញវត្ថុរបស់ឃុំ គឺគំរោងមានតំលៃខ្ពស់។ សមាជិកក្រុមប្រឹក្សាម្នាក់បានពន្យល់ថា "បញ្ហាគឺជាប់ទាក់ទងនឹងការដេញថ្លៃគំរោង"។ អ្នកដេញថ្លៃគំរោងឯកភាពគ្នាលើតំលៃខ្ពស់មួយ ហើយគេកំណត់យកតំលៃដូចគ្នា (កិច្ចសម្ភាសន៍១៧)។ បញ្ហានេះទាក់ទងការដេញថ្លៃគំរោង ដែលឈ្មួញកំណត់យកតំលៃខ្ពស់ ធ្វើឱ្យក្រុមប្រឹក្សាបង្ខំចិត្តអនុវត្តន៍គំរោងតូចៗជាងអ្វីដែលបានគ្រោងទុក។ បញ្ហានេះអាចកើតឡើងដោយសារក្រុមប្រឹក្សាមិនមានជំនាញបច្ចេកទេស និងបទពិសោធន៍ក្នុងការងារលទ្ធកម្ម។

# រចនាសម្ព័ន្ធ និង ការគ្រប់គ្រងរដ្ឋបាល

នៅផ្នែកនេះ ការស្រាវជ្រាវគឺចង់ផ្តោតទៅលើរចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាជាពិសេស ក្រុមស្រាវជ្រាវចង់ដឹងថាតើស្ត្រីនឹងអនុវត្តន៍កិច្ចការក្រុមប្រឹក្សាដោយរបៀបណា ហើយមានបញ្ហាប្រឈមអ្វីខ្លះក្នុងការងារប្រចាំថ្ងៃ។ លើទិដ្ឋភាពនយោបាយ ក្រុមការងារចង់ដឹងថាតើភាពមិនចុះសំរុងគ្នារវាងសមាជិកបក្សនយោបាយផ្សេងៗ ធ្វើឱ្យប៉ះពាល់ដល់ការងារក្រុមប្រឹក្សាដែរឬទេ។

## ១- សមាជិកក្រុមប្រឹក្សាស្ត្រី

សង្កាត់ទាំងអស់ មានសមាជិកក្រុមប្រឹក្សាស្ត្រីម្នាក់ លើកលែងតែសង្កាត់លេខ៩។ ក្រុមប្រឹក្សាឃុំលេខ១០នេះមានមេភូមិភាគច្រើនជាស្ត្រី ដែលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។ ចៅសង្កាត់លេខ៧ជាស្ត្រី។ សមាជិកក្រុមប្រឹក្សាស្ត្រីចំនួន៤នាក់ក្នុងសង្កាត់៨ បានចូលរួមយ៉ាងសកម្មក្នុងការងារដូចសមាជិកក្រុមប្រឹក្សាបុរសដែរ។ គាត់ទទួលបន្ទុកផងដែរ ក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគំរោងរបស់ក្រុមប្រឹក្សា (កិច្ចសម្ភាសន៍៨)។ ក្រុមប្រឹក្សាយល់ឃើញថា វាមានសារៈសំខាន់ក្នុងការដែលមានសមាជិកក្រុមប្រឹក្សាជាស្ត្រី។

អនុលោមតាមមាត្រា១៩នៃអនុក្រិត្យលេខ២២ សមាជិកក្រុមប្រឹក្សាឃុំត្រូវតែងតាំងស្ត្រី១នាក់ទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ។ ៩១.២%នៃក្រុមប្រឹក្សាដែលបានបំពេញសំនួរបាននិយាយថា គំរោងរបស់ក្រុមប្រឹក្សាបានផ្តោតជាពិសេសលើបញ្ហាស្ត្រី។ តែចំណុចនេះមិនអាចបញ្ជាក់បានទេ នៅក្នុងការសំភាសន៍ដោយផ្ទាល់ជាមួយក្រុមប្រឹក្សា។ នៅក្នុងគំរោងផែនការរបស់ក្រុមប្រឹក្សា មិនមានគំរោងលើកឡើងពីបញ្ហាយែនឌ័រទេ។ ឆ្លើយនឹងសំនួរជំរុញស្ត្រីឱ្យឈរឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាស្ត្រីម្នាក់បានពន្យល់ថា

ចាំបាច់ ត្រូវមានការបណ្តុះបណ្តាលពីសិទ្ធិស្ត្រី ដើម្បីឱ្យមានស្ត្រីច្រើនចាប់អារម្មណ៍ក្នុងការសហ ការជាមួយក្រុមប្រឹក្សា ឬឈរឈ្មោះជាក្រុមប្រឹក្សា។ ជាការមួយមានសារៈសំខាន់នៅក្នុង ការបណ្តុះបណ្តាលពីសិទ្ធិស្ត្រី មិនចំពោះទិសដៅក្នុងការជំរុញស្ត្រីឱ្យចូលរួម ក្នុងការងារ នយោបាយក៏ដោយ ក៏អាចឱ្យស្ត្រីជាច្រើនមានការចាប់អារម្មណ៍ចូលរួមបន្ថែមទៀតដែរ។
ចៅសង្កាត់៧ជាស្ត្រីបាននិយាយថា នាពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងជំរុញស្ត្រីឱ្យចូលរួមក្នុងនយោបាយ ធ្វើឱ្យគាត់មានទឹកចិត្តរិតតែខិតខំបំពេញការងារថែមទៀត។ គាត់បានព្យាយាមជំរុញស្ត្រីជាច្រើនឱ្យចូលរួមក្នុងនយោបាយ ដោយពន្យល់ថា ស្ត្រីអាចរៀន និងស្វែងយល់ពីបទពិសោធន៍ក្នុងពេលបំពេញការងារជាក្រុមប្រឹក្សា ដោយមិនចាំបាច់យល់ពីការងារទាំងអស់ពីដំបូងនោះទេ ឬរៀន ហើយអនុវត្តន៍ការងារតែម្តង។

ក្រុមប្រឹក្សាស្ត្រីនៅសង្កាត់លេខ៥បាននិយាយថា ជាទូទៅវាមានការលំបាកក្នុងការ បំពេញការងារជាក្រុមប្រឹក្សា នៅពេលដែលស្ត្រីធ្វើនយោបាយផង និងជាមេផ្ទះផង។ ជាហេតុធ្វើឱ្យក្រុមប្រឹក្សាស្ត្រីធ្វើការងារច្រើនជាងក្រុមប្រឹក្សាបុរស (កិច្ចសម្ភាសន៍៥) ក៏ដូចជាការមិនគោរពក្រុមប្រឹក្សាស្ត្រីពីសំណាក់ក្រុមប្រឹក្សាបុរស ដោយមិនរំពឹងថាស្ត្រីអាចធ្វើការដូចបុរស អាចជាហេតុផលមួយដែរ ក្នុងការដែលមានចំនួនស្ត្រីតិច ក្នុងការងារនយោបាយ។ ក្រុមប្រឹក្សាភាគច្រើនបានយល់ឃើញបែបនេះ នៅពេលបំពេញសំនួរសម្ភាសន៍។ មូលហេតុមួយទៀតនោះ គឺខ្វះជំនឿទុកចិត្តលើខ្លួនឯង (៧៥%នៃក្រុមប្រឹក្សា បានលើកឡើង) ដែលអាចដោះស្រាយតាមរយៈការបណ្តុះបណ្តាល។

ឆ្លើយនឹងសំនួរពីចំនួនភាគរយតិចនៃស្ត្រីជាសមាជិកក្រុមប្រឹក្សា ៥៥% បាននិយាយថាស្ត្រីមិនមានជំនឿលើខ្លួនឯង នៅក្នុងការឈរឈ្មោះជាក្រុមប្រឹក្សា។ ការបណ្តុះបណ្តាលអំពីសិទ្ធិស្ត្រី លទ្ធភាពក្នុងការចូលរួមការងារ នយោបាយមូលដ្ឋាន ការរៀបចំការប្រជុំរវាងស្ត្រីជាមួយនឹងសមាជិកក្រុមប្រឹក្សាស្ត្រី អាចបង្កើនជំនឿទុកចិត្តដល់ស្ត្រីឱ្យឈរ ឈ្មោះជាក្រុមប្រឹក្សា។ ៤២.៥%នៃក្រុម ប្រឹក្សា បានសន្និដ្ឋានថាស្ត្រីមិនមានពេល គ្រប់គ្រាន់សំរាប់ការងារនេះ។ គណបក្សនយោបាយក៏មានតួនាទីសំខាន់ផងដែរៈ ក្រុមប្រឹក្សា៣៥% បានយល់ឃើញថា ការដែលគណបក្សនយោបាយមិនដាក់ស្ត្រី នៅលំដាប់លើនៃបញ្ជីឈ្មោះបេក្ខជន ក៏ជាមូលហេតុមួយដែលមានស្ត្រីតិចតួចក្នុងក្រុមប្រឹក្សា (តារាង ៦)។

| មូលហេតុដែលមិនមានស្ត្រីច្រើនជាសមាជិកក្រុមប្រឹក្សា | ចំលើយ | ភាគរយ |
|---|---|---|
| នយោបាយគណបក្ស | ១៤ | ៣៥.០០ |
| ស្ត្រីមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | ១០ | ២៥.០០ |
| ស្ត្រីមិនមានពេលវេលាគ្រប់គ្រាន់ | ១៧ | ៤២.៥០ |
| ស្ត្រីមិនមានជំនឿទុកចិត្តលើខ្លួនឯង | ២២ | ៥៥.០០ |
| ស្វាមីមិនអនុញ្ញាតឱ្យចូលរួមការងារនយោបាយ | ១១ | ២៧.៥០ |
| មូលហេតុផ្សេងៗទៀត | ១១ | ២៧.៥០ |
| សរុប | ៨៥ | |

តារាង៦: មូលហេតុដែលមិនមានស្ត្រីច្រើនជាសមាជិកក្រុមប្រឹក្សា

នៅតាមឃុំដែលក្រុមការងារធ្វើសម្ភាសន៍ មិនសូវមានសមាជិកក្រុមប្រឹក្សាជាស្ត្រីទេ ហើយក៏មិនបានសម្ភាសន៍ក្រុមប្រឹក្សាស្ត្រីដែរ។ នៅក្នុងឃុំដែលមិនមានក្រុមប្រឹក្សាជាស្ត្រី ក្រុមប្រឹក្សាមានអ្នកស្ម័គ្រចិត្តជួយការងារស្ត្រីនិងកុមារ និងចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាផ្តល់ប្រាក់ខែពី៣០.០០០ ទៅ៤០.០០០រៀលក្នុង

មួយខែ។ គំរោងស្តីពីយែនឌ័រភាគច្រើនផ្តោតលើអំពើហិង្សាក្នុងគ្រួសារ និងការអប់រំពីសុខភាពបន្តពូជ (កិច្ចសម្ភាសន៍ទី៣)។

ក្នុងឃុំដែលមិនមានស្ត្រីជាក្រុមប្រឹក្សា ការចាត់ចែងឱ្យមានស្ត្រីទទួលការងារយែនឌ័រ ជាការបង្ហាញនូវការយកចិត្តទុកដាក់ពីសុខទុក្ខរបស់ស្ត្រីនៅក្នុងគោលនយោបាយនៅមូលដ្ឋាន។ ទន្ទឹមគ្នានោះស្ត្រីដែលបំពេញការងារនេះអាចទទួលបាននូវបទពិសោធន៍អំពីវិមជ្ឈការ លើកឡើងនូវគំនិតរបស់ខ្លួន កសាងនូវការជឿជាក់លើខ្លួនឯងក្នុងការបំពេញការងារជាមួយក្រុមប្រឹក្សាបុរសនិងប្រជាពលរដ្ឋនៅក្នុងឃុំ។ ស្ត្រីទាំងនេះអាចឈរឈ្មោះជាបេក្ខភាពក្រុមប្រឹក្សាឃុំ-សង្កាត់នាខែមេសាឆ្នាំ២០០៧ ហើយអាចឋិតនៅលំដាប់ខ្ពស់នៃបញ្ជីឈ្មោះរបស់គណបក្ស បើសិនគាត់បំពេញការងារបានល្អ។

## ២- កិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយ

ការស្រាវជ្រាវ គឺផ្តោតចំបងលើដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា និងមិន ផ្តោតលើបញ្ហានយោបាយទេ។ ផ្នែកនេះផ្តោតលើទំនាក់ទំនងរវាងគណបក្សនយោបាយ។ ក្រុមប្រឹក្សាដែលបានសម្ភាសន៍មានសមាសភាពច្រើនគណបក្ស ប្រធានក្រុមប្រឹក្សាជាសមាជិកបក្សប្រជាជន។ ក្រុមប្រឹក្សាបាននិយាយថា មានការសហការល្អរវាងគណបក្សនយោបាយ និងមិនមានបញ្ហាអ្វីចំពោះនយោបាយគណបក្សទេ។ នៅពេលដែលសួរអំពីមូលហេតុដែលនាំឱ្យមានសហប្រតិបត្តិការល្អបែបនេះ គឺមានមូលហេតុ៤: ទីមួយក្រុមប្រឹក្សា ចង់បំរើប្រជាជននៅក្នុងឃុំរបស់ខ្លួន។ ទោះបីជាក្រុមប្រឹក្សាមកពីគណបក្សផ្សេងៗគ្នាក៏ដោយគេមានទិសដៅនេះដូចគ្នា (កិច្ចសម្ភាសន៍ទី៨ និងទី៩)។ ទីពីរគឺដោយសារក្រុមប្រឹក្សាមានភារកិច្ចផ្សេងៗពីគ្នា។ ចៅសង្កាត់៤បានពន្យល់ថា បញ្ហាអាចដោះស្រាយបានដោយសារមានមេឃុំម្នាក់ជាអ្នកសំរបសំរួលបញ្ហា។ ទីបីសមាជិកក្រុមប្រឹក្សាមួយចំនួនបាននិយាយថា មានបញ្ហាជាមួយនឹងសមាជិកដែលមកពីគណបក្សផ្សេងៗគ្នា

តែអាចដោះស្រាយបាន នៅពេលដែលគេបានស្គាល់ពីគ្នាទៅវិញទៅមក (កិច្ចសម្ភាសន៍ ទី២)។ ទី៤ សមាជិកក្រុមប្រឹក្សាត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងមានការដាក់វិន័យនៅពេលដែលមានការបំពាន ឬមិនបំពេញភារកិច្ចរបស់ខ្លួន។ វិធានការរួមមាន ការរាយការណ៍ដល់អាជ្ញាធរថ្នាក់លើអំពីកំហុសក្រុមប្រឹក្សានោះ (កិច្ចសម្ភាសន៍ ទី១០)។

សំនួរដែលបំពេញដោយក្រុមប្រឹក្សាមកពីបក្សសមរង្ស៊ីបានបង្ហាញពី កិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយនេះ។ គាត់បាននិយាយថា នៅមានការរើសអើងផ្នែកនយោបាយចំពោះមតិប្រឆាំង។ តាមការរៀបរាប់របស់ក្រុមប្រឹក្សាមកពីបក្សប្រជាជនឃើញថាកិច្ចសហប្រតិបត្តិការ និងការយោគយល់គ្នារវាងគណបក្សនយោបាយ មិនបានដំណើរការទៅរលូន ដូចដែលក្រុមប្រឹក្សាបាននិយាយនោះទេ។ ពេលដែលសួរអំពីការសហការនេះ ក្រុមប្រឹក្សាម្នាក់បានឆ្លើយថាៈ "ចំពោះយើងនៅក្នុងគណបក្សប្រជាជនមិនមានបញ្ហាទេ តែចំពោះអ្នកផ្សេងមានការលំបាក។ ក្រុមប្រឹក្សាមកពីគណបក្សពីរផ្សេងទៀតខ្វះចំណេះដឹង និងយល់បានតិចតួចពីវគ្គបណ្តុះបណ្តាល" (កិច្ចសម្ភាសន៍ទី៣)។ ក្រុមស្រាវជ្រាវ មិនមានព័ត៌មានបន្ថែមទៀតទេ ដោយសារមិនបានពិភាក្សាពីបញ្ហានយោបាយ និងបានសម្ភាសន៍តែជាមួយក្រុមប្រឹក្សាមកពីគណបក្សប្រជាជន។

## ៣_ ការសហការជាមួយនឹងមេភូមិ

ក្រុមប្រឹក្សាកោតសរសើរការជួយរបស់មេភូមិ ព្រោះគាត់បានលើកឡើងពីសារៈសំខាន់របស់មេភូមិ។ សារៈសំខាន់របស់មេភូមិចំពោះក្រុមប្រឹក្សា អាចជាការពិចារណានៅក្នុងការបណ្តុះបណ្តាលមេភូមិអំពីវិមជ្ឈការ និងជាពិសេសអំពីការធ្វើផែនការអភិវឌ្ឍន៍។

ក្រុមប្រឹក្សាបានលើកពីសារៈសំខាន់នេះថា "បើគ្មានជំនួយពីមេភូមិទេ ក្រុមប្រឹក្សាមិនអាចបំពេញការងារបានទេ" (កិច្ចសម្ភាសន៍ទី១៤)។ មេភូមិជាជនបង្គោល ព្រោះគាត់នៅជិតនឹងប្រជាពលរដ្ឋ ហើយអាចប្រមូលព័ត៌មានពីប្រជាពលរដ្ឋបានដោយស្រួល

(កិច្ច សម្ភាសន៍ទី១)។ ព័ត៌មានដែលទទួលបានពីមេភូមិ មានរួមទាំងសេចក្តីត្រូវការរបស់អ្នកភូមិពាក់ព័ន្ធនឹងការធ្វើផែនការអភិវឌ្ឍន៍ និងការងាររដ្ឋបាល ដូចជាការធ្វើអត្តសញ្ញាណប័ណ្ណ (កិច្ចសម្ភាសន៍ទី៦)។ ក្រុមប្រឹក្សានិងមេភូមិក៏បានសហការជាមួយគ្នាលើការងារសន្តិសុខ ឬកសិកម្ម (កិច្ចសម្ភាសន៍ទី៩)។ ក្នុងឃុំ១៧ ក្រុមប្រឹក្សាបាននិយាយថា ក្រុមប្រឹក្សាអាចធានាការងារសន្តិសុខបាន គឺដោយសារជំនួយពីមេភូមិ (កិច្ចសម្ភាសន៍ទី១៧)។ នៅសង្កាត់លេខ៣ ក្រុមប្រឹក្សាជួបជាមួយនឹងមេភូមិក្នុងមួយខែម្តង។ នៅឃុំខ្លះ មេភូមិតំណាងឱ្យប្រជាពលរដ្ឋ នៅក្នុងការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា (កិច្ចសម្ភាសន៍ទី៣)។

ជាទូទៅមេភូមិបានដឹងពីសេចក្តីសំរេចរបស់ក្រុមប្រឹក្សា ហើយផ្តល់ព័ត៌មាននេះបន្តទៅប្រជាពលរដ្ឋ (កិច្ចសម្ភាសន៍ទី៤)។ មេភូមិដើរតួជាអ្នកនាំពាក្យរវាងក្រុមប្រឹក្សានិងប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាទុកចិត្តលើមេភូមិជាអ្នកផ្សព្វផ្សាយអំពីការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាទៅឱ្យប្រជាពលរដ្ឋ។ នៅឃុំ១៧ ប្រជាពលរដ្ឋមិនបានចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាទេ តែមេភូមិបានចូលរួមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាក៏បានជួយមេភូមិដែរ ដូចជាមេភូមិពិបាកអញ្ជើញអ្នកភូមិមកប្រជុំ ព្រោះគាត់មិនមានអំណោយចែកឱ្យតែក្រុមប្រឹក្សាមានអំណោយ (កិច្ចសម្ភាសន៍ទី៣)។

កិច្ចសហការរវាងមេភូមិនិងក្រុមប្រឹក្សាក៏មានចោទជាបញ្ហាខ្លះដែរ។ មេភូមិមិនមានវត្តមានគ្រប់ការប្រជុំរបស់ក្រុមប្រឹក្សាទេ ដោយសារគាត់មិនមានពេលគ្រប់គ្រាន់ (កិច្ចសម្ភាសន៍ទី១២)។ ឃុំមួយបានប្រឈមមុខនឹងបញ្ហាលំបាកដោយសារមេភូមិមិនសហការៈ "នៅពេលដែលយើងឱ្យការងារដល់គាត់ គាត់មិនធ្វើ អាចថាគាត់មិនចេះធ្វើ។ យើងចង់ឱ្យមានការបណ្តុះបណ្តាលដល់គាត់ (កិច្ចសម្ភាសន៍១១)។

កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ មិនមែនសុទ្ធតែទទួលបានលទ្ធផលជាវិជ្ជមានទាំងអស់ទេ ទោះបីជាក្រុមប្រឹក្សាត្រូវការជំនួយពីរដ្ឋាភិបាលក្នុងការអនុវត្តវិមជ្ឈការឱ្យបានត្រឹមត្រូវក៏ដោយ។ ក្រុមប្រឹក្សាឃុំ១០បានលើកឡើងថា ប៉ូលីសមិនបានប្រាប់ក្រុមប្រឹក្សាអំពីសកម្មភាពរបស់គេនៅក្នុងឃុំទេៈ "ពួកគេមិនគោរពយើងទេ" (កិច្ចសម្ភាសន៍១០)។ ការលើកឡើងនេះបញ្ជាក់ថា ក្រុមប្រឹក្សាបានចាត់ទុកប៉ូលីស និងកងរាជអាវុធហត្ថជាអ្នកតំណាងឱ្យរដ្ឋាភិបាល។ នេះបង្ហាញពីទំនាក់ទំនងដ៏ស្មុគស្មាញមួយនៅថ្នាក់មូលដ្ឋាន។

## ៤_ ដំណោះស្រាយជម្លោះ

ក្រុមប្រឹក្សាបាននិយាយថា គាត់មិនមានសមត្ថភាពក្នុងការកាត់ក្តី នៅពេលភាគីក្នុងជម្លោះមិនទទួលយកការសំរបសំរួល។ ករណីដូចនេះត្រូវបញ្ជូនទៅតុលាការ។ ក្រុមប្រឹក្សាបាននិយាយថា ក្រុមប្រឹក្សាអនុវត្តដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំនងឱ្យមាននូវការសំរបសំរួលជាជាងការគុំគួនគ្នាទៅវិញទៅមក (កិច្ចសម្ភាសន៍ទី៨)។ ក្រុមប្រឹក្សាខ្លះមានគណៈកម្មការដោះស្រាយជម្លោះ (កិច្ចសម្ភាសន៍២ និង១១) ដែលមានសមាសភាពជាព្រឹទ្ធាចារ្យ មេភូមិ និងព្រះសង្ឃ។ នៅឃុំផ្សេងទៀតគឺជំទប់ជាអ្នកផ្តល់ដំបូន្មានដល់ពលរដ្ឋ (កិច្ចសម្ភាសន៍៨ និង៩)។ វិធិសាស្ត្រនេះអនុវត្តន៍ផងដែរ នៅតាមសង្កាត់។ នៅសង្កាត់លេខ៤ ជំទប់ទី២មានភារកិច្ចជាអ្នកដោះស្រាយជម្លោះ។

ពីបញ្ហាទំនាស់នៅក្នុងឃុំ ក្រុមប្រឹក្សាបានលើកឡើងពីជម្លោះដីធ្លី និងអំពើហិង្សាក្នុងគ្រួសារ។ ក្រុមប្រឹក្សានៅក្នុងឃុំ១បាននិយាយថា ទំនាស់ដីធ្លីជាទំនាស់ស្រួចស្រាវជាងគេនាពេលបច្ចុប្បន្ន (កិច្ចសម្ភាសន៍១)។

ក្រុមប្រឹក្សាមិនបានដោះស្រាយគ្រប់បញ្ហាទាំងអស់របស់ប្រជាជនទេ។ បើមានបញ្ហាធ្ងន់ធ្ងរក្រុមប្រឹក្សាបានឱ្យយោបល់ទៅដោះស្រាយនៅតុលាការ (កិច្ចសម្ភាសន៍៣)

ឬរកដំណោះស្រាយជាមួយក្រុមប្រឹក្សា ព្រោះបើទៅតុលាការ ត្រូវចំណាយច្រើន (កិច្ចសម្ភាសន៍៧)។ បញ្ហានៅត្រង់ថា ប្រជាពលរដ្ឋមិនធ្វើតាមក្រុមប្រឹក្សាគ្រប់ពេលនោះទេ: ក្រុមប្រឹក្សានៅឃុំលេខ១២បានឱ្យដឹងថា ក្រុមប្រឹក្សាអាចដោះស្រាយបានតែជំលោះមួយចំនួនតូចប៉ុណ្ណោះ ព្រោះប្រជាពលរដ្ឋមិនស្តាប់តាមយោបល់ក្រុមប្រឹក្សាគ្រប់ករណីនោះទេ (កិច្ចសម្ភាសន៍១២)។ ក្រុមប្រឹក្សាខ្លះថា គ្មានបញ្ហាកើតឡើងនៅក្នុងឃុំរបស់គាត់ទេ ប្រការនេះពិបាកជឿណាស់ នៅពេលដែលអំពើហិង្សាក្នុងគ្រួសារមានកើតឡើងជាច្រើន។ ជាប្រការមួយវិជ្ជមាន ដែលប្រជាពលរដ្ឋបានឱ្យក្រុមប្រឹក្សាជួយដោះស្រាយជម្លោះ សរឱ្យឃើញថាក្រុមប្រឹក្សាបានទទួលនូវការគោរពពីសហគមន៍។

# ការចូលរួមរបស់ប្រជាពលរដ្ឋ

វិមជ្ឈការតំរូវឱ្យមានការចូលរួមច្រើនពីប្រជាពលរដ្ឋ។ បើប្រជាពលរដ្ឋអសកម្ម មិនចូលរួម ការអនុវត្តវិមជ្ឈការនឹងមិនទទួលបានជោគជ័យទេ។ ហេតុនេះ ព័ត៌មានស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ មានសារៈសំខាន់ណាស់ ដើម្បីបានដឹងពីដំណើរការវិមជ្ឈការនាពេលបច្ចុប្បន្ន។ ផ្នែកនេះនឹងពិនិត្យពីការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការប្រជុំរបស់ឃុំ-សង្កាត់ ពីទស្សនៈរបស់ក្រុមប្រឹក្សាពីការចូលរួមនេះ ភាពចាំបាច់នៃការសហការរវាងតំណាងម្ចាស់ឆ្នោត និងប្រជាពលរដ្ឋ ឱកាសនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ ច្បាប់បានតំរូវឱ្យមានអ្នកភូមិចូលរួមក្នុងការងាររបស់ឃុំ ដែលខិតខំប្រឹងប្រែងឱ្យមានការចូលរួមនេះ។ បើសិនជាស្ថានភាពជាក់ស្តែងមិនអំណោយផលទេ ឃុំប្រាកដជាមានការលំបាកក្នុងការសំរេចនូវគោលដៅនេះ។ ឧទាហរណ៍ថា ទីកន្លែងប្រជុំក្រុមប្រឹក្សានៅឆ្ងាយពីផ្ទះប្រជាពលរដ្ឋប្រាកដជាលំបាកក្នុងការទាក់ទាញប្រជាពលរដ្ឋឱ្យចូលរួម។

## ១- ការចូលរួមរបស់ប្រជាពលរដ្ឋ

ដើម្បីវាយតំលៃពីការងារប្រចាំថ្ងៃ ភារកិច្ច និងបញ្ហាប្រឈម ក្រុមប្រឹក្សាត្រូវបានសម្ភាសន៍ពីការចូលរួមរបស់ប្រជាពលរដ្ឋ។ ក្រុមស្រាវជ្រាវបានទទួលព័ត៌មានគួរឱ្យចាប់អារម្មណ៍ ហើយបានធ្វើការប្រៀបធៀបជាមួយនឹងលទ្ធផលនៃការបំពេញសំនួរ។ ជាទូទៅក្រុមប្រឹក្សាមានការលំបាកក្នុងការជំរុញឱ្យអ្នកភូមិចូលរួមដំណើរការវិមជ្ឈការ។

មានលទ្ធភាពពីរយ៉ាងដែលប្រជាពលរដ្ឋចូលរួមការងារក្រុមប្រឹក្សាៈ

ក- ចូលរួមជាប្រាក់វិភាគទានក្នុងសកម្មភាពអភិវឌ្ឍន៍។ ក្រុមប្រឹក្សាបានដើរទៅតាមផ្ទះអ្នកភូមិ ដើម្បីប្រមូលទុនចូលរួមតាមដែលអាចធ្វើបាន។ ចំពោះអ្នកក្រីក្រអាចផ្តល់វិភាគទានតិចតួច ឬមិនមានទាល់តែសោះ។ "បើសិនប្រជា

ពលរដ្ឋចូលរួមនោះគេប្រាកដជាថែរក្សាផ្លូវ ព្រោះមានចំណែកលុយរបស់គេ" (កិច្ចសម្ភាសន៍ទី៧)។ តាមសំដីនេះ ទុនចូលរួមរបស់ប្រជាពលរដ្ឋមានអត្ថប្រយោជន៍ពីរៈ ជួយកសាងផ្លូវ ហើយមានការទទួលខុសត្រូវចំពោះផ្លូវ ធ្វើឱ្យកាត់បន្ថយចំណាយនៃការថែរក្សាផ្លូវ។ រដ្ឋាភិបាលតំរូវឱ្យសហគមន៍ចូលរួមទុន១០%នៃគំរោងអភិវឌ្ឍន៍ ទើបរដ្ឋាភិបាលផ្តល់នូវចំនួនដែលនៅសេសសល់។

ខ- ក្រៅពីនេះ ប្រជាពលរដ្ឋចូលរួមធ្វើផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ។ គេផ្តល់គំនិត និងសំណូមពរនូវគំរោងថ្មីៗ។ ក្រុមប្រឹក្សាខ្លះបានកំណត់ចំនួនប្រជាពលរដ្ឋចូលរួម ខ្លះទៀតគ្រាន់តែសង្ឃឹមថានឹងមានការចូលរួមច្រើនពីប្រជាពលរដ្ឋ។ "យើងមានគំរោងថ្មីជារៀងរាល់ឆ្នាំ មួយឆ្នាំ-គំរោងមួយ។ យើងបានកំណត់ឱ្យក្នុងមួយគ្រួសារ ត្រូវមានសមាជិកម្នាក់ចូលរួម" (កិច្ចសម្ភាសន៍ទី៩)។ ទាក់ទងនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ ប្រជាពលរដ្ឋមានការចូលរួមច្រើន។ នៅក្នុងសង្កាត់ខ្លះ ក្រុមប្រឹក្សាបានព្យាយាមឱ្យអ្នកដែលចាប់អារម្មណ៍ចូលរួមទាំងអស់ តាមរយៈការប្រជុំនៅខាងក្រៅដើម្បីគេអាចឃើញ និងចូលរួម (កិច្ចសម្ភាសន៍ទី៨)។

ក្រុមប្រឹក្សាជាច្រើនបានសំដែងពីការកង្វល់ និងខកចិត្តចំពោះការមិនអើពើរបស់ប្រជាពលរដ្ឋ។ អាចមានហេតុផលច្រើន។ ភាគច្រើន ប្រជាពលរដ្ឋមិនចាប់អារម្មណ៍ចំពោះការងារក្រុមប្រឹក្សាដែលបំពេញសំរាប់សហគមន៍ៈ "ប្រជាពលរដ្ឋមិនខ្វល់អំពីក្រុមប្រឹក្សាទេ គេគិតតែពីការងារជំនួញរបស់គេ" (កិច្ចសម្ភាសន៍ទី៤)។ ក្រុមប្រឹក្សាម្នាក់បាននិយាយថា "ប្រជាពលរដ្ឋមិនយកចិត្តទុកដាក់នឹងព័ត៌មាន ដែលបិទនៅលើក្តារព័ត៌មានទេ គេគិតតែអំពីជីវភាពរស់នៅរបស់គេតែប៉ុណ្ណោះ" (កិច្ចសម្ភាសន៍ទី៣)។ ក្រុមប្រឹក្សាចាត់ទុកថាបញ្ហានេះអាចបណ្តាលមកពីក្រុមប្រឹក្សា និងលទ្ធភាពរបស់ក្រុមប្រឹក្សាៈ

"ក្រុម ប្រឹក្សាមិនមានសមត្ថភាពគ្រប់គ្រាន់ ប្រជាពលរដ្ឋបានប្រាប់យើងថា ចង់ធ្វើអ្វីធ្វើទៅ គាត់មិនខ្វល់ទេ" (កិច្ចសម្ភាសន៍ទី១៤)។ ក្រុមប្រឹក្សាមានការលំបាកក្នុងការធ្វើឱ្យប្រជា ពលរដ្ឋចូលរួមៈ ហេតុផលគឺ ប្រជាពលរដ្ឋក្រ មិនចាប់អារម្មណ៍ក្នុងការចូលរួម ឬ ជាប់រវល់នឹងការងារ។ នៅក្នុងសង្កាត់មួយ គ្មានការសហការពីពលរដ្ឋទេ ក្រៅពីការចូលរួមរបស់មេភូមិក្នុងកិច្ចប្រជុំ (កិច្ចសម្ភាសន៍ទី៧)។

ក្រុមប្រឹក្សាខ្លះលើកឡើងពីសមត្ថភាពអ្នកចូលរួមៈ "មិនសូវមានប្រជាពលរដ្ឋច្រើនចូលរួមការប្រជុំទេ ហើយបើមកក៏មិនមានគំនិតអ្វីដែរ។ ទោះជាយ៉ាងណាក៏មានស្ត្រី ជួយការងារក្រុមប្រឹក្សា និងមេភូមិចូលរួមការប្រជុំ។ យើងអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួម ពិភាក្សាអំពីផែនការអភិវឌ្ឍន៍ បើមិនអញ្ជើងគេមិនមកទេ។ យើងបានបែងចែកប្រជាពល រដ្ឋជាពីរក្រុមគឺក្រុមបុរស និងក្រុមស្ត្រី តែគេនៅតែគ្មានគំនិត" (កិច្ចសម្ភាសន៍១៥)។ គ្រាន់តែចូលរួមប្រជុំមិនមានន័យថាចូលរួមទេ ប្រការសំខាន់ត្រូវផ្តោតលើលទ្ធភាពនៃការចូលរួមធ្វើការសំរេចចិត្ត។ ក្រុមប្រឹក្សាបានរិះរកមធ្យោបាយនានា ដើម្បីទាក់ទាញប្រជាពលរដ្ឋ។ ជំរើសមួយគឺឱ្យអំណោយជាម្ហូបៈ ប្រជាជនក្រីក្រចូលរួមច្រើន អ្នកមានទ្រព្យសម្បត្តិមិនចាប់អារម្មណ៍នឹងអំណោយនេះទេ (កិច្ចសម្ភាសន៍ទី៣)។ វិធីសាស្ត្រមួយទៀតគឺលិខិតអញ្ជើញមានលេខហើយ នៅពេលប្រជុំយើងធ្វើការចាប់ឆ្នោត" (កិច្ចសម្ភាសន៍ទី៤)។ ក្រុមស្រាវជ្រាវសង្កេតឃើញថា ក្រុមប្រឹក្សាបានរិះរកវិធីជាច្រើនដើម្បីឱ្យប្រជាពលរដ្ឋចូលរួម។ ការឱ្យអំណោយដើម្បីឱ្យប្រជាពលរដ្ឋចូលរួម ជាប្រការមួយមិនល្អទេ ហើយអាចជាបញ្ហាចំពោះការចូលរួមក្នុងសកម្មភាពនានារបស់គណបក្សនយោបាយ ឬ ពេលបោះឆ្នោត។

វិធីមួយទៀត គឺធ្វើការជ្រើសរើសតំណាងបន្ថែមរបស់ពលរដ្ឋ ដូចជាតំណាងរបស់ជនជាតិម៉ូស្លីម តំណាងស្ត្រី ឬព្រឹទ្ធាចារ្យដែលត្រូវបានអញ្ជើញចូលរួមប្រជុំជាមួយក្រុមប្រឹក្សាជាជាងអញ្ជើញអ្នកភូមិទាំងអស់៖ "គេបានដឹងអំពីតំណាងក្រុមរបស់គេ" (កិច្ចសម្ភាសន៍ទី១)។ ប្រជាពលរដ្ឋ ឬក្រុមប្រឹក្សាជាអ្នកជ្រើសរើសតំណាងទាំងនោះ៖ "យើងបានសំរេចចិត្តអញ្ជើញតែតំណាង ព្រោះប្រជាពលរដ្ឋជាប់រវល់ (កិច្ចសម្ភាសន៍ទី៥)។ សង្កាត់មួយចំនួនបានប្រើប្រាស់វិធីសាស្ត្រនេះ ដែលអាចជាដំណោះស្រាយជាក់ស្តែងចំពោះការចូលរួម ទោះបីជាមើលទៅហាក់ដូចជាមិនបើកទូលាយឱ្យសាធារណៈជនជាទូទៅបានចូលរួមប្រជុំ (កិច្ចសម្ភាសន៍ទី៩)។

ការលើកឡើងរបស់មេឃុំ បានបញ្ជាក់បន្ថែមពីការលំបាក ក្នុងការធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋ៖ បញ្ហាមួយទៀតនៃការចូលរួមមិនគ្រប់គ្រាន់ គឺគេមិនផ្តល់ទុនចូលរួមបានច្រើនទេ។ ប្រជាពលរដ្ឋមិនចាប់អារម្មណ៍និងមិនចង់ចូលរួម (កិច្ចសម្ភាសន៍ទី១១)។ ទោះបីជាយ៉ាងនេះក្តី ក៏មានសញ្ញាណវិជ្ជមានដែរ។ ក្រុមប្រឹក្សាម្នាក់បាននិយាយថា ឥឡូវនេះមានការងាយស្រួលជាងប្រាំឆ្នាំមុន ក្នុងការអញ្ជើញប្រជាពលរដ្ឋចូលរួម (កិច្ចសម្ភាសន៍ទី១៨)។ ប្រជាពលរដ្ឋដែលចូលរួម បានយល់អំពីដំណើរការវិមជ្ឈការ។ បង្ហាញឱ្យឃើញថា មានការជឿនលឿន ព្រោះប្រជាពលរដ្ឋបានដឹងពីការចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាន។ ភាពជោគជ័យនៃការចូលរួមរបស់ប្រជាពលរដ្ឋគឺ ស្ថិតនៅលើស្នាដៃរបស់ក្រុមប្រឹក្សា។ បើសិនជាគំរោងមិនបានចាប់ផ្តើមធ្វើ ឬធ្វើបញ្ចប់ដូចដែលបានគ្រោងទុក ប្រជាជននឹងបាត់បង់ជំនឿលើក្រុមប្រឹក្សា ក្នុងការផ្លាស់ប្តូរស្ថានភាពរស់នៅ និងមានអារម្មណ៍ថាការចូលរួមរបស់គាត់មិនមានជាលទ្ធផលអ្វីទេ។

## ២. ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះការចូលរួម

កថាខណ្ឌនេះផ្តោតលើទស្សនៈរបស់ប្រជាពលរដ្ឋ ពីតួនាទីរបស់គាត់ចំពោះក្រុមប្រឹក្សា និងដំណើរការវិមជ្ឈការ។ ៦៣.១% នៃអ្នកសម្ភាសន៍បានដឹងអំពីការងារ

ក្រុមប្រឹក្សា (តារាង៧)។ នេះជាតួលេខមួយខ្ពស់។ ៩៤.១% បានដឹងពីទីតាំងការិយាល័យឃុំ។ ដូចនេះ អ្នកដែលមិនដឹងពីការងារក្រុមប្រឹក្សាអាចដឹងពីកន្លែងដែលអាចទទួលបានព័ត៌មានប្រសិនបើគាត់ចង់ដឹង។ ៤៨% បាននិយាយថា គេបានអញ្ជើញគាត់ឱ្យចូលរួម

ឱ្យចូលរួមការប្រជុំ។ ក្រុមប្រឹក្សាគួរតែផ្សព្វផ្សាយ ឱ្យប្រជាពលរដ្ឋដឹងថា ពួកគេអាចចូលរួមស្តាប់ កិច្ចប្រជុំនានា របស់ក្រុមប្រឹក្សាបាន ប្រសិន បើគេចង់ចូលរួម។ ៨៨.៥% និយាយថាគាត់ចង់ ដឹងឱ្យបានច្រើនអំពីការងារក្រុមប្រឹក្សា ។ នេះជា សញ្ញាជាវិជ្ជមានមួយ ដែលក្រុមប្រឹក្សាត្រូវយក ការចាប់អារម្មណ៍នេះដើម្បីជុំរុញការងារក្រុមប្រឹក្សា។

| ចំលើយ | ចំនួន | ភាគរយ |
|---|---|---|
| ដឹង | ១៦៦ | ៦៣.១០ |
| មិនដឹង | ៩៧ | ៣៦.៩០ |
| សរុប | ២៦៣ | ១០០.០០ |
| អវត្តមាន | ៨ | |
| សរុបរួម | ២៧១ | |

តារាង៧: តើអ្នកបានដឹងអំពីការងារក្រុមប្រឹក្សាឃុំសង្កាត់ដែរឬទេ?

ប្រជាពលរដ្ឋ មានការអាក់អន់ផងដែរចំពោះការបំពេញការងារក្រុមប្រឹក្សា។ ២១.៥% បាននិយាយថាក្រុមប្រឹក្សា មិនបានផ្តួចផ្តើមអ្វីដើម្បី កែប្រែជីវភាពរស់នៅរបស់គាត់ក្នុងអំឡុងប្រាំឆ្នាំនេះទេ។ ៣០.២% មិនទុកចិត្តថាក្រុមប្រឹក្សា នឹងប្រើប្រាស់លុយឱ្យបានត្រឹមត្រូវក្នុងការជួយសហគមន៍ទេ (តារាង៨)។ ការខ្វះជំនឿទុកចិត្តនេះ នឹងចោទជាឧបសគ្គដល់ការសហការដ៏ជោគជ័យរវាងក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។

| ចំលើយ | ចំនួន | ភាគរយ |
|---|---|---|
| ទុកចិត្ត | ១៨០ | ៦៩.៨ |
| មិនទុកចិត្ត | ៧៨ | ៣០.២ |
| សរុប | ២៥៨ | ១០០.0 |
| អវត្តមាន | ១៣ | |
| សរុបរួម | ២៧១ | |

តារាង៨: តើអ្នកទុកចិត្តក្រុមប្រឹក្សាក្នុងការប្រើប្រាស់លុយឱ្យបានត្រឹមត្រូវដើម្បីជួយសហគមន៍ដែរឬទេ?

ទោះជាយ៉ាងណាក៏ដោយ នៅមានចំនុចជាវិជ្ជមានជាច្រើនផងដែរ ដូចជា ៣៥.៤% បានចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាម្តងដង ឬច្រើនដង ហើយ ៩១.៩% បានឆ្លើយថាក្រុមប្រឹក្សានៅទីនេះដើម្បីជួយប្រជាពលរដ្ឋ។

ជាសរុបចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ ការបណ្តុះបណ្តាលគួរផ្តោតលើលទ្ធភាពនៃការចូលរួមជាជាងសិទ្ធិនៃការចូលរួម។ ទស្សនះកិច្ចឃុំ_សង្កាត់ គំរូអាចជំរុញផងដែរចំពោះការចូលរួម។

## ៣. ទស្សនៈរបស់ក្រុមប្រឹក្សាពីការចូលរួម

ពីសិទ្ធិនៃការចូលរួមការប្រជុំ ក្រុមប្រឹក្សា៩៧% បានឆ្លើយថា ប្រជាពលរដ្ឋមានសិទ្ធិចូលរួម។ ចំលើយនេះបានបង្ហាញថា ក្រុមប្រឹក្សាយល់ដឹងច្រើនអំពីតួនាទីក្នុងការចូលរួមរបស់ប្រជាពលរដ្ឋ។

ស្តីពីការជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការសំរេចចិត្តរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សានិយាយថា បានពឹងពាក់មេភូមិដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋអំពីការងារក្រុមប្រឹក្សា។ មធ្យោបាយមួយទៀតគឺ អញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមប្រជុំ ឬបិទផ្សាយលើក្តារពត៌មាន ដែលមានចែងនៅក្នុងច្បាប់ឱ្យក្រុមប្រឹក្សាធ្វើការផ្សព្វផ្សាយនូវព័ត៌មាននានា។

៨៩.៤% បាននិយាយថា មូលហេតុដែលប្រជាពលរដ្ឋមិនចូលរួមគឺគាត់ជាប់រវល់នឹងការងារ។ ៤៥.៥%ថា គាត់មិនចាប់អារម្មណ៍ការងារក្រុមប្រឹក្សា (តារាង៩)។ ២៧.៣% និយាយថា ឧបសគ្គដ៏ធំបំផុតចំពោះជោគជ័យនៃវិមជ្ឈការ គឺកង្វះការចូលរួមពីប្រជាពលរដ្ឋ។

| តើហេតុផលអ្វីដែលពលរដ្ឋមិនចូលរួម ? | ចំនួន | ភាគរយ |
|---|---|---|
| គ្មានពេលវេលា ការងារច្រើន | ៥៩ | ៨៩.៤០ |
| មិនចាប់អារម្មណ៍នឹងការងារក្រុមប្រឹក្សា | ៣០ | ៤៥.៥០ |
| មិនយល់ដឹងពីនយោបាយ | ២៩ | ៤៣.៩០ |
| មានការភ័យខ្លាច | ៨ | ១២.១០ |
| មិនអញ្ជើញគាត់ឱ្យចូលរួម | ១០ | ១៥.២០ |
| ហេតុផលផ្សេងទៀត | ១៤ | ២១.២០ |
| សរុប | ១៥០ | |

តារាង៩: តើហេតុផលអ្វីដែលប្រជាពលរដ្ឋមិនចូលរួម?

តាមការសម្ភាសន៍ជាមួយក្រុមប្រឹក្សាមានចំនុចមួយ នៃការងាររបស់ក្រុមប្រឹក្សាដែលប្រជាពលរដ្ឋបានចូលរួម គឺការធ្វើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ៩៥% និយាយថាប្រជាពលរដ្ឋបានចូលរួម។

ក្រុមប្រឹក្សានិយាយថា ប្រជាពលរដ្ឋមានសិទ្ធិចូលរួម ក្នុងការប្រជុំក្រុមប្រឹក្សាមានន័យថា គាត់យល់ដឹងអំពីច្បាប់ទាក់ទងនឹងការចូលរួមរបស់ពលរដ្ឋ។ ប៉ុន្តែបើ

ពិនិត្យពីការអនុវត្តច្បាប់វិញ រូបភាពហាក់ដូចជាមិនវិជ្ជមាន។ ៩៨% បានអញ្ជើញប្រជាពលរដ្ឋតាមរយៈមេភូមិ ៨៥% បានអញ្ជើញដោយផ្ទាល់ ហើយ ៧០% បានបិទប្រកាសលើក្តារព័ត៌មាន (តារាង១០)។

| | ចំនួន | ភាគរយ |
|---|---|---|
| បិទប្រកាស ឬក្តារពត៌មាន | ៤៧ | ៧០.១០ |
| មេភូមិ | ៦៦ | ៩៨.៥០ |
| ការអញ្ជើញជាលក្ខណៈបុគ្គល | ៥៧ | ៨៥.១០ |
| មធ្យោបាយផ្សេងៗទៀត | ២២ | ៣២.៨០ |
| សរុប | ១៩២ | |

តារាង១០: តើអ្នកធ្វើដូចម្តេចដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួម?

ក្រុមប្រឹក្សាបានសន្និដ្ឋានថា អ្នកទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ សហគមន៍ជាក្រុមប្រឹក្សា មេភូមិ និងប្រជាពលរដ្ឋទាំងអស់គ្នា។ ក្រុមប្រឹក្សាមួយចំនួនតូចគិតថា ជាការទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិ។ ការរកឃើញនេះសមស្របជាមួយលទ្ធផលផ្សេងៗទៀត និងមានអារម្មណ៍ថា ក្រុមប្រឹក្សាមានការចាប់អារម្មណ៍ ឱ្យមានមតិយោបល់ពីប្រជាពលរដ្ឋ។

# ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

ក្រុមប្រឹក្សាដែលបានសម្ភាសន៍ បានចាប់ផ្តើមអនុវត្តន៍ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ខ្លួន។ គំរោងផែនការត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ជាពិសេសនៅពេលលើកផែនការ ក្រុមប្រឹក្សាតែងតែបញ្ចូលគំនិតរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាទទួលប្រាក់វិភាជន៍ពីរដ្ឋាភិបាលប្រចាំឆ្នាំ តាមទំហំនៃឃុំ និងចំនួនប្រជាពលរដ្ឋ។ ថវិកាដែលទទួលបាននោះ មួយផ្នែកត្រូវយកទៅអនុវត្តន៍គំរោងអភិវឌ្ឍន៍ទំហំតូចនៅតាមភូមិ និងសហគមន៍។ ប្រជាពលរដ្ឋត្រូវចូលរួមទុនចំពោះគំរោង ជាការផ្តល់ឱកាសឱ្យគាត់បានឃើញផ្ទាល់ពីលទ្ធផលនៃទុនចូលរួមរបស់គាត់។ "យើងទៅផ្ទះប្រជាពលរដ្ឋដើម្បីដឹងពីសេចក្តីត្រូវការ ហើយលើកគំរោងផែនការតាមសេចក្តីត្រូវការនោះ។ យើងមានគណៈកម្មាធិការទទួលការងារនេះ។ ប្រជាពលរដ្ឋចូលរួមទុនពី១០ ទៅ១៥%នៃតំលៃគំរោង (កិច្ចសម្ភាសន៍ ទី២)។

## ១. ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

ផ្នែកនេះផ្តោតលើការយល់ដឹងរបស់ក្រុមប្រឹក្សា អំពីគំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងលទ្ធផលដែលសំរេចបាននៅក្នុងអាណត្តិទី១។

ការធ្វើផែនការអភិវឌ្ឍន៍គឺផ្អែកលើដំណើរការ១១ជំហានកំណត់ដោយរដ្ឋាភិបាលៈ "យើងមានគំរោង៥ឆ្នាំផ្តោតលើ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន រដ្ឋបាល និងយែនឌ័រ។ យើងឱ្យប្រជាពលរដ្ឋសរសេរនូវអ្វីដែលជាតំរូវការចាំបាច់របស់គាត់។ ពេលបានព័ត៌មានហើយ យើងផ្តល់អាទិភាពថាត្រូវកសាងផ្លូវមួយណាមុន។ ប្រជាពលរដ្ឋចូលរួមកិច្ចការនេះ ព្រោះគាត់ចង់ឱ្យបានផ្លូវល្អជាងមុន ងាយស្រួលដឹកជញ្ជូនផលិតផលរបស់គាត់ (កិច្ចសម្ភាសន៍ ទី៤)។

ក. ជំហានទីមួយគឺ ក្រុមប្រឹក្សាត្រូវមានការប្រជុំពិភាក្សាអំពីគំរោងដែលត្រូវការ និងថវិការបស់ឃុំ។ ការប្រជុំនេះផ្តល់ជាគំនិតដំបូងឱ្យក្រុមប្រឹក្សា។

ខ. ជំហានបន្ទាប់ ក្រុមប្រឹក្សាឬមេភូមិស្វែងរកមតិ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ឃុំនីមួយៗមានការអនុវត្តផ្សេងៗពីគ្នា។ នៅក្នុងឃុំខ្លះមានគណៈកម្មាធិការទទួលបន្ទុកធ្វើផែនការ និងសាកសួរប្រជាពលរដ្ឋអំពីបញ្ហា និងចំណុចកែលំអ។ ជួនកាលអាចអញ្ជើញប្រជាពលរដ្ឋនិងមេភូមិឱ្យចូលរួមប្រជុំម្តងទៀត។

គ. គំនិតដែលទទួលពីការប្រជុំនេះ ត្រូវយកទៅពិភាក្សានៅឃុំ ហើយផ្តល់អាទិភាពដោយក្រុមប្រឹក្សា ពេលខ្លះមានការចូលរួមពីមេភូមិដែរ។

វិធីជាទូទៅមួយទៀតនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ តាមប្រសាសន៍មេឃុំ (ការសម្ភាសន៍ទី៥) "ការធ្វើផែនការអភិវឌ្ឍន៍បានធ្វើឡើងក្នុងពេលប្រជុំ ដែលមានការចូលរួមពីក្រុមប្រឹក្សា មេភូមិ អ្នកតំណាង ប្រជាពលរដ្ឋ និងអ្នកស្ម័គ្រចិត្តសហគមន៍ ដោយផ្តោតលើប្រធានបទមួយចំនួន។ បន្ទាប់មក ធ្វើការសាកសួរប្រជាពលរដ្ឋ ហើយឱ្យគាត់សរសេរពីសេចក្តីត្រូវការ ដែលឃុំយកមកកំណត់ជាអាទិភាព។ យើងប្រាប់ប្រជាពលរដ្ឋថា ការសាងផ្លូវគឺសំរាប់សហគមន៍ទាំងមូល។ ប្រជាពលរដ្ឋយល់ពីបញ្ហានេះ ហើយបានចូលរួមប្រាក់វិភាគទាន (កិច្ចសម្ភាសន៍ទី៥)។

ផែនការអភិវឌ្ឍន៍ភាគច្រើនផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ និងអណ្តូងទឹក ព្រោះជាតំរូវការនិងបំណងប្រាថ្នារបស់គាត់។ នៅតាមសង្កាត់ គំរោងអភិវឌ្ឍន៍ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធលូ។ ជាប្រការមួយគួរឱ្យចាប់អារម្មណ៍ ដែលសង្កាត់បានចាត់ទុកផ្លូវនិងលូជាអាទិភាព។ សង្កាត់ខ្លះបានប្រាប់ពីចំនួនផ្លូវដែលបានសាងសង់ ដែលបានសំរួលដល់ការរស់នៅរបស់ពលរដ្ឋនៅក្នុងសង្កាត់។

ប្រការដែលក្រុមប្រឹក្សាកសាងផ្លូវ និងលូ ព្រោះប្រជាពលរដ្ឋអាចឃើញលទ្ធផលនៃការរួមចំណែករបស់គាត់ កសាងជំនឿទុកចិត្តលើក្រុមប្រឹក្សា។ ផ្លូវស្អាតក៏ជានិមិត្តរូបមួយដែលអាចឃើញទាំងអស់គ្នា។ ឃុំដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ អាចចាត់ទុកថាមានការរីកចំរើន និងជោគជ័យក្នុងក្រសែភ្នែកនៃអ្នកភូមិ។ លើសពីនេះ កសាងផ្លូវជាការងាយស្រួលក្នុងការលើកផែនការ ដោយគ្រាន់តែជួលសហគ្រិន ហើយទទួលលទ្ធផលក្នុងរយៈពេលខ្លី។ ឃុំប្រាកដជាមានការលំបាកជាង នៅក្នុងការបង្ក្រាបបទឧក្រិដ្ឋ ឬបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ។ បើសិនជាកសាងផ្លូវមិនបានល្អ ឃុំនឹងជួបប្រទះបញ្ហាទឹកជំនន់ បន្ទាប់ពីភ្លៀងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់ការប្រកបរបររបស់ប្រជាពលរដ្ឋ។

ជាទូទៅ ក្រុមប្រឹក្សាមានការពេញចិត្តនឹងលទ្ធផលដែលទទួលបាន។ គាត់ទទួលស្គាល់ថា មិនបានបំពេញអស់នូវគំរោងដែលបានលើកឡើយ ដោយសារកង្វះថវិកា និងការចូលរួមរបស់ពលរដ្ឋ ដោយមិនលើកពីកង្វះខាតនៃការបំពេញភារកិច្ចរបស់ខ្លួនឡើយ (កិច្ចសម្ភាសន៍ទី១)។ ក្រុមប្រឹក្សាបាន និយាយថាមានការអភិវឌ្ឍន៍ជាច្រើននៅក្នុងសហគមន៍ ដូចជាសាលារៀន ផ្សារ និងផ្លូវល្អជាដើម: "ទាំងនេះគឺដោយសារគំរោងបានចេញពីពលរដ្ឋ ពីក្រុមប្រឹក្សា មិនមែនមកពីថ្នាក់លើទៀតទេ"។ ទន្ទឹមនឹងការសំរេចបាននូវសមិទ្ធិផលមួយចំនួននេះ ក្រុមប្រឹក្សានៅមានការប្រឈមនឹងបញ្ហាផ្សេងទៀតទាក់ទងនឹងគំរោងអភិវឌ្ឍន៍: "ប្រជាពលរដ្ឋមិនសប្បាយចិត្តទេបើជួសជុលតែផ្លូវមួយ ហើយមិនជួសជុលផ្លូវផ្សេងទៀត។ ពេលមានផ្លូវថ្មី គេក៏មិននិយាយថាផ្លូវថ្មីផ្តល់ក្តីសង្ឃឹមនោះទេ" (កិច្ចសម្ភាសន៍ទី៣)។

ពេលខ្លះមានការខុសគ្នាឆ្ងាយរវាងភាពប្រឈមដែលឃុំជួបប្រទះ និងការធ្វើផែនការអភិវឌ្ឍន៍។ ក្រុមប្រឹក្សាម្នាក់បានលើកឡើងអំពីបញ្ហាសន្តិសុខដែលសង្កាត់ជួបប្រទះ ក៏ប៉ុន្តែគំរោងអភិវឌ្ឍន៍ផ្តោតលើផ្លូវ និងលូទៅវិញ។ ពេលចោទសួរពីដំណោះស្រាយបញ្ហាសន្តិសុខ គាត់ឆ្លើយថាសន្តិសុខមិនមែនជាបញ្ហាថវិកា និងវិនិយោគដូចផ្លូវទេ (កិច្ច

សម្ភាសន៍ទី១០)។ ក្រុមស្រាវជ្រាវបានសួរក្រុមប្រឹក្សាមួយទៀតថា ហេតុអ្វីបានជាផែនការអភិវឌ្ឍន៍ផ្តោតលើផ្លូវ និងលូ បើបញ្ហាគឺភាពក្រីក្រ និងសន្តិសុខ។ គាត់ឆ្លើយថា "នេះគ្រាន់តែជាជំហានដំបូងដើម្បីកាត់បន្ថយភាពក្រីក្រ"។ ចំពោះដំណាក់កាលបន្តទៀត គាត់មិនដឹងទេ ព្រោះគាត់ជិតបញ្ចប់អាណត្តិហើយ (កិច្ចសម្ភាសន៍ទី៧)។

ឆ្លងតាមការសម្ភាសន៍ឃើញថា ក្រុមប្រឹក្សាមានបំណងប្រាថ្នាចង់ឱ្យមានភាពផ្លាស់ប្តូរមុខមាត់ថ្មី ហើយមានការតូចចិត្ត ដោយមិនអាចបំពេញតាមសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ : "ប្រជាពលរដ្ឋត្រូវការច្រើន តែយើងមិនអាចបំពេញតាម គ្រប់សេចក្តីត្រូវការនោះទេ។ ប្រជាពលរដ្ឋនឹងតវ៉ា បើគ្មានផ្លូវនៅមុខផ្ទះគាត់" (កិច្ច សម្ភាសន៍ទី៥)។

បញ្ហាមួយទៀតគឺបញ្ហាហិរញ្ញវត្ថុ។ ក្រុមប្រឹក្សានិយាយថាៈ "យើងមិនអាចនិយាយថា ថវិកាដែលទទួលបានពីរដ្ឋាភិបាលមិនគ្រប់គ្រាន់នោះទេ តែបើបានច្រើនជាងនេះ ជាការប្រសើរ។ បើទទួលបានជោគជ័យឆ្នាំនេះ ឆ្នាំក្រោយនឹងទទួលបានថវិកាបន្តទៀត។ តែបើបរាជ័យ គេនឹងយកលុយទៅវិញ" (កិច្ចសម្ភាសន៍ទី៧)។ មេឃុំម្នាក់បានផ្តោតលើបញ្ហាប្រមូលលុយពីប្រជាពលរដ្ឋៈ "គំរោងផែនការអភិវឌ្ឍន៍ផ្តោតលើបញ្ហាសន្តិសុខ កសិកម្ម ការបណ្តុះបណ្តាល។ បញ្ហាគឺទុនចូលរួមរបស់ប្រជាពលរដ្ឋ គេព្រងើយកន្តើយ ពេលដែលយើងស្នើសុំលុយពីគេ (កិច្ចសម្ភាសន៍ទី១០)។ ប្រការនេះអាចធ្វើឱ្យក្រុមប្រឹក្សាមានការលំបាក នៅក្នុងការធ្វើគំរោងអភិវឌ្ឍន៍រយៈពេលវែង ព្រោះគំរោងអាចមានតំលៃខ្ពស់ជាង ហើយត្រូវការច្រើនឆ្នាំដើម្បីបានលទ្ធផលជារូបរាង។

ក្រុមប្រឹក្សាបានទទួលកាបណ្តុះបណ្តាល ពីការធ្វើផែនការអភិវឌ្ឍន៍ ប៉ុន្តែបានសំណូមពរសុំឱ្យមានការរំលឹកលើប្រធានបទនេះថែមទៀត។ បញ្ហាមួយទៀតគឺការដេញថ្លៃ។ ក្រុមប្រឹក្សាខ្វះជំនាញបច្ចេកទេស ដើម្បីវាយតម្លៃពីគុណភាពការងារក្រុមហ៊ុនដេញ

ថ្ងៃគំរោង។ មានបាតុភាពពីការសាងសង់ផ្លូវមិនមានគុណភាព ២ឆ្នាំក្រោយមក ផ្លូវខូច ហើយត្រូវការជួសជុលឡើងវិញ (កិច្ចសម្ភាសន៍ទី១៧)។

ទស្សនៈដែលទទួលបានពីការសម្ភាសន៍បង្ហាញថា ដំណើរការវិមជ្ឈការបានធ្វើឱ្យមានការផ្លាស់ប្តូរមួយ ពីរបៀបនៃការអនុវត្តគំរោងអភិវឌ្ឍន៍នៅមូលដ្ឋានៈ "យើងធ្វើការផ្អែកលើមតិយោបល់របស់ប្រជាពលរដ្ឋ។ យើងផ្តោតលើកសិកម្ម និងកសាងផ្លូវ។ ប្រជាពលរដ្ឋជួយកសាងប្រព័ន្ធធារាសាស្ត្រ តែយើងមិនអាចបង្ខំគាត់ឱ្យធ្វើដូចកាលសម័យខ្មែរក្រហមនោះទេ វាចិតនៅលើការសំរេចចិត្តរបស់គាត់ (កិច្ចសម្ភាសន៍ទី៩)។ ផ្តើមចេញពីនេះ ឃើញថាសំលេងរបស់ប្រជាពលរដ្ឋមានឥទ្ធិពល។ សំលេងនេះនៅខ្សោយ តែបើប្រជាពលរដ្ឋចង់ផ្តល់គំនិត ក្រុមប្រឹក្សាភាគច្រើននឹងផ្តល់ឱកាសឱ្យគាត់ចូលរួម។

## ២_ ទស្សនៈរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សា បានទទួលការបណ្តុះបណ្តាលពីការធ្វើផែនការអភិវឌ្ឍន៍។ ៨៧% ពេញចិត្តនឹងលទ្ធផល នៃការអនុវត្តគំរោងអភិវឌ្ឍន៍ ហើយចាត់ទុកជាជោគជ័យមួយ (តារាងទី ១១)។

| | ចំនួន | ភាគរយ |
|---|---|---|
| ទទួលបានលទ្ធផលល្អ_ជោគជ័យ | ៤៧ | ៨៧.00 |
| លំបាកតែយើងខិតខំបញ្ចប់គំរោង | ៤ | ៧.៤0 |
| យោបល់ផ្សេងៗទៀត | ៣ | ៥.៦0 |
| សរុប | ៥៤ | ១00.00 |
| អវត្តមាន | ១៤ | |
| សរុប | ៦៨ | |

តារាង១១: តើអ្នកយល់យ៉ាងណាចំពោះការធ្វើគំរោងផែនការអភិវឌ្ឍន៍

ចោទសួរពីការទទួលខុសត្រូវ អភិវឌ្ឍន៍សហគមន៍ ក្រុមប្រឹក្សាបានឆ្លើយថា គឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា មេភូមិ និងអ្នកភូមិ។ នេះបង្ហាញថាក្រុមប្រឹក្សាទទួលស្គាល់ពីតួនាទីនៃភាគីទាំងបី ហើយការអភិវឌ្ឍន៍ត្រូវចាប់ផ្តើមពីសហគមន៍ខ្លួនឯងផ្ទាល់។ ក្រុមប្រឹក្សាដឹងថា មិនមែនរដ្ឋាភិបាលតែម្នាក់ទេ ដែលផ្តល់ការអភិវឌ្ឍន៍ឱ្យ

សហគមន៍។ ចំពោះគំរោងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ក្រុមប្រឹក្សាបានផ្តោតលើការសាងសង់ផ្លូវ និងសំណង់។ ការកសាងផ្លូវអាចរួមចំណែកលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រោះជួយសំរួលការធ្វើដំណើរទៅសាលារៀន និងយកកសិផលទៅទីផ្សារ (តារាងទី១២)។

| | ចំនួន | ភាគរយ |
|---|---|---|
| កសាងផ្លូវ និងសំណង់ | ៦៤ | ៩៧.០០ |
| ការអប់រំនិងអក្ខរកម្មរួមទាំងការសាងសង់សាលា | ៥០ | ៧៥.៨០ |
| លើកកំពស់សុខភាព | ៥៨ | ៨៧.៩០ |
| លើកកំពស់ស្ថានភាពស្ត្រី | ៥៥ | ៨៣.៣០ |
| បញ្ហាផ្សេងៗទៀត | ១៩ | ២៨.៨០ |
| សរុប | ២៤៦ | |

តារាងទី១២: តើគំរោងអភិវឌ្ឍន៍ផ្តោតលើអ្វី

## ៣_ ទស្សនៈប្រជាពលរដ្ឋចំពោះផែនការអភិវឌ្ឍន៍

ជាការបង្ហាញនូវការជឿជាក់ ប្រជាពលរដ្ឋបាននិយាយថា ក្រុមប្រឹក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរមុខមាត់ (តារាង ១៣)។ ៤០.១%ទទួលស្គាល់ថា ក្រុមប្រឹក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំមួយ នៅក្នុងការអភិវឌ្ឍន៍សហគមន៍ ។ ៥៣%គិតថា មានការផ្លាស់ប្តូរតិចតួច ហើយសំណូមពរឱ្យមានគំរោងច្រើនជាងនេះ នៅអាណត្តិក្រោយ។ ៧% ថាក្រុមប្រឹក្សាមិនបានធ្វើឱ្យមានការខុសប្លែកអ្វីទេ ចំពោះជីវភាពរស់នៅរបស់គាត់។ មានការខុសគ្នាបន្តិចចំពោះទិន្នន័យ ដែលទទួលបានគឺ ៥១.៩% ថាមិនដែលបានដឹងពីគំរោងអភិវឌ្ឍន៍ទេ (តារាង១៤)។ អាច

| | ចំនួន | ភាគរយ |
|---|---|---|
| មានធ្វើការផ្លាស់ប្តូរច្រើន | ១១៥ | ៤០.១ |
| មានតិចតួចសំណូមពរឱ្យមានគំរោងច្រើន | ១៥២ | ៥៣.០ |
| គ្មានអ្វីផ្លាស់ប្តូរទេ | ២០ | ៧.០ |
| សរុប | ២៨៧ | ១០០.០ |

តារាង១៣: តើអ្នកគិតថាក្រុមប្រឹក្សាធ្វើឱ្យមានការអភិវឌ្ឍន៍នៅក្នុងឃុំរបស់អ្នកឬទេ?

| | ចំនួន | ភាគរយ |
|---|---|---|
| ដឹង | ១១៧ | ៤៨.១០ |
| មិនដឹង | ១២៦ | ៥១.៩០ |
| សរុប | ២៤៣ | ១០០.០០ |
| អវត្តមាន | ២៨ | |
| សរុបរួម | ២៧១ | |

តារាង១៤: តើអ្នកធ្លាប់ដឹងពីផែនការអភិវឌ្ឍន៍ទេ ?

សន្និដ្ឋានថា ប្រជាពលរដ្ឋមិនដែលឮពីគំរោង ឬគាត់មិនចង់និយាយមិនល្អពីការគ្រប់គ្រងនៅមូលដ្ឋាន។

ក្រុមប្រឹក្សាបានយល់ពី"ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម" ហើយចាត់ទុកថាជាត្រីវិស័យសំរាប់ដឹកនាំការងារក្រុមប្រឹក្សា និងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍។ ក្រុមប្រឹក្សាប្រមូលគំនិតពីប្រជាពលរដ្ឋ តែមិនប្រើប្រាស់គំនិតទាំងស្រុង ដើម្បីកំណត់ការងារដែលត្រូវធ្វើទេ។ ដូចនេះគំរោងភាគច្រើនផ្តោតលើ ការកសាងផ្លូវ និងប្រព័ន្ធលូ នៅពេលដែលសេចក្តីត្រូវការរបស់ពលរដ្ឋមានច្រើន និងស្មុគស្មាញ។ ជាការពិតដែលថា ឃុំខិតខំដោះស្រាយបញ្ហាធំៗដូចជាសន្តិសុខ គ្រឿងញៀន (នៅទីក្រុង) និងភាពក្រីក្រ។ ការលើកគំរោងប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនេះមានការលំបាកនឹងទទួលបានជោគជ័យ

ជាការងាយស្រួលជាងក្នុងការជ្រើសរើសការកសាងផ្លូវ។ ប្រការនេះអាចធ្វើឱ្យប៉ះពាល់ទាំងក្រុមប្រឹក្សា និងម្ចាស់ទុនចូលរួម។ ក្រុមស្រាវជ្រាវយល់ឃើញថា គួរបណ្តុះបណ្តាលក្រុមប្រឹក្សាអំពីការពង្រីកគំរោងអភិវឌ្ឍន៍។

# សេចក្ដីសន្និដ្ឋាន

ការជួបសម្ភាសន៍ជាមួយក្រុមប្រឹក្សា បានផ្ដល់ព័ត៌មានពីស្ថានភាពនៃការអនុវត្ត វិមជ្ឈការនៅកម្ពុជា នៅតំបន់ទីក្រុង និងជនបទ។ ទោះបីជាមិនអាចធ្វើការសន្និដ្ឋាន ជារួមនៅទូទាំងប្រទេស ដោយសារចំនួន និងការជ្រើសរើសអ្នកសម្ភាសន៍ ក៏យើងអាច ឃើញនូវនិន្នាការនានាដែលស្ដែងឡើងនៅតាមឃុំ-សង្កាត់ដែលបានសម្ភាសន៍។

ជាទូទៅ នៅទីក្រុងភ្នំពេញក្រុមប្រឹក្សាយល់ដឹងពីភារកិច្ចរបស់គាត់ ថាត្រូវបំពេញ កិច្ចការដែលអាជ្ញាធរជាតិបានធ្វើប្រតិភូកម្មឱ្យ និងបំរើប្រជាពលរដ្ឋដោយបំពេញតាម សេចក្ដីត្រូវការ និងជំរុញការអភិវឌ្ឍន៍។ ព្រមគ្នានោះដែរ ក្រុមប្រឹក្សាគិតថាដំណើរការ វិមជ្ឈការជាការងារលំបាក ហើយហួសពីលទ្ធភាពនិងសមត្ថភាពរបស់គាត់។ គាត់មិនដឹង ថាត្រូវអនុវត្តសកម្មភាពយ៉ាងដូចម្ដេច។

ការបណ្ដុះបណ្ដាលបន្ថែមពីមុខជំនាញដែលពាក់ ព័ន្ធជាការចាំបាច់។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ចាត់ទុកការរួមវិភាគទានរបស់ខ្លួននៅក្នុងការអភិវឌ្ឍន៍ សហគមន៍ជាភារកិច្ចសំខាន់ និងទទួលបានជោគជ័យតាមកំរិតផ្សេងៗគ្នា។ ប្រការដែល គួរចាប់អារម្មណ៍គឺ គំរោងបានផ្ដោតលើហេដ្ឋារចនាសម្ព័ន្ធ (ការកសាងផ្លូវ និងប្រព័ន្ធ លូ)។ គំរោងទាំងនេះបានជួយអ្នកមានជីវភាពធូធារ ឯអ្នកក្របានទទួលតិចតួចប៉ុណ្ណោះ។ ដូចនេះ គួរបញ្ចូលសេចក្ដីត្រូវការរបស់អ្នកទីទល់ក្របំផុតនៅក្នុងផែនការអភិ វឌ្ឍន៍ឃុំ។

ក្រុមប្រឹក្សាបានពន្យល់ថាៈ "ការអនុវត្តទៅតាមក្របខ័ណ្ឌច្បាប់មានការលំបាក ព្រោះវិមជ្ឈការជាដំណើរការថ្មីសំរាប់កម្ពុជា។ នេះជាក្ដីសង្ឃឹមមួយ ដោយសារក្រុមប្រឹក្សា នឹងរៀនសូត្រតាមការអនុវត្តជាក់ស្ដែង។ ក្រុមប្រឹក្សាគិតថា បញ្ហានឹងអាចដោះស្រាយ បន្តិចម្ដងៗ នៅពេលដែលវិមជ្ឈការឈានចូលទៅក្នុងអាណត្តិទីពីរ។ ក្រុមប្រឹក្សាមើល

ឃើញការបណ្តុះបណ្តាលផ្តល់ឱ្យដោយម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលនានា ជាការជួយក្រុមប្រឹក្សាដោះស្រាយបញ្ហា និងឱ្យយល់ដឹងពីក្របខណ្ឌច្បាប់។ ស្ថានភាពហិរញ្ញវត្ថុស្ដួចស្ដើងជាឧបសគ្គមួយទៀត ដែលសុំឱ្យមានការគាំទ្រក្រុមប្រឹក្សាជាហិរញ្ញវត្ថុ ឬបណ្តុះបណ្តាលពីរបៀបស្នើសុំជំនួយ។ ក្រុមប្រឹក្សាពឹងផ្អែកលើការសហការរបស់មេភូមិដើម្បីបំពេញភារកិច្ច។ ប្រការនេះធ្វើឱ្យក្រុមប្រឹក្សាបានដឹងពីលទ្ធភាព និងសមត្ថភាពរបស់ខ្លួនថា វិមជ្ឈការអាចអនុវត្តបានដោយជោគជ័យលុះត្រាតែមានដៃគូ។

ទំនាក់ទំនងអំណាចនៅមូលដ្ឋានក៏ដើរតួសំខាន់ផងដែរ។ ក្រុមប្រឹក្សាភាគច្រើនបានចូលរួមការងារនយោបាយមូលដ្ឋានតាំងពីទស្សវត្សទី៨០។ ចំនួនលើសលប់នៃសមាជិកក្រុមប្រឹក្សាបុរសបង្ហាញឱ្យឃើញថា ស្ត្រីនៅមិនទាន់មានអាទិភាពក្នុងនយោបាយមូលដ្ឋាននៅឡើយ។ គណបក្សប្រជាជនកម្ពុជា ជាគណបក្សនយោបាយឈានមុខគេ ដែលភាគច្រើននៃមេឃុំជាសមាជិករបស់គណបក្ស។ កង្វះសមាជិកក្រុមប្រឹក្សាស្ត្រី និងគណបក្សប្រឆាំងមួយខ្សោយ អាចឈានទៅនយោបាយឯកត្ត។ គួរមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីឱ្យដឹងថា គំរោងលើកឡើងដោយក្រុមប្រឹក្សា បានបំពេញនូវសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋបានក៏រិតណា។

កត្តាវិជ្ជមានមួយស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋគឺ គេបានដឹងពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ក្រុមប្រឹក្សាមានការងាយស្រួលនៅក្នុងការឱ្យប្រជាពលរដ្ឋចូលរួមក្នុងការងារនេះ។ ប្រជាពលរដ្ឋជាច្រើន បានចូលរួមការប្រជុំ និងបានផ្តល់គំនិតពីគំរោងដែលគាត់ចង់បាននៅក្នុងឃុំរបស់គាត់។ ក្រុមប្រឹក្សាបានសំរេចចិត្តឱ្យប្រជាពលរដ្ឋចូលរួមវិភាគទានក្នុងគំរោង តាមលទ្ធភាពដែលប្រជាពលរដ្ឋមាន។

មានប្រជាពលរដ្ឋតិចតួចណាស់ ដែលចាប់អារម្មណ៍ពីការងារឃុំ-សង្កាត់ ក្រុមប្រឹក្សាថា ប្រជាពលរដ្ឋមិនយល់ពីសារៈសំខាន់នៃការចុះសំបុត្រកំណើត និងសំបុត្រអាពាហ៍ពិពាហ៍ទេ។ ស្ទើរតែគ្មានប្រជាពលរដ្ឋចូលរួមការប្រជុំប្រចាំខែ របស់ឃុំ-សង្កាត់។ អាច

បណ្តាលមកពីក្រុមប្រឹក្សាមិនបានប្រាប់ថា ប្រជាពលរដ្ឋមានសិទ្ធិចូលរួម និងលើកពីគំនិតរបស់ខ្លួន។ នៅពេលអនាគត គួរយកចិត្តទុកដាក់ក្នុងការជំរុញឱ្យប្រជាពលរដ្ឋចូលរួមឱ្យបានទៀងទាត់ក្នុងការអភិវឌ្ឍសហគមន៍។ កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សានឹងនាំឱ្យមានការគោរពតួនាទីទាំងសងខាង។

វិមជ្ឈការជារបត់មួយសំខាន់ណាស់ សំរាប់ប្រជាធិបតេយ្យដ៏ក្មេងខ្ចីរបស់កម្ពុជា ហើយអ្នកដែលមានពាក់ព័ន្ធនៅក្នុងដំណើរការនេះ ចាំបាច់ត្រូវការជំនួយឧបត្ថម្ភទាំងអស់ ដើម្បីធានានូវជោគជ័យនៃវិមជ្ឈការ។

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យត្រូវបានបង្កើតជាអង្គការក្រៅរដ្ឋាភិបាលនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩២ ដោយក្រុមប្រជាជនកម្ពុជា_អាមេរិច។

ការងាររបស់វិទ្យាស្ថានគឺដើម្បីជំរុញតំលៃលទ្ធិប្រជាធិបតេយ្យនៅក្នុងសង្គមកម្ពុជា ដោយប្រកាន់នូវនយោបាយអព្យាក្រឹត្យ។ វិទ្យាស្ថានមានសកម្មភាពមួយចំនួន ដើម្បីជំរុញសណ្តាប់ធ្នាប់នៃលទ្ធិប្រជាធិតេយ្យសេរីនិយម ដូចការកំណត់ដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ដោយផ្អែកលើប្រព័ន្ធលទ្ធិប្រជាធិតេយ្យសេរីពហុបក្ស សិទ្ធិមនុស្ស និងការគោរពច្បាប់ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យបានក្លាយជាដៃគូរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ នៅឆ្នាំ១៩៩៤។

ផ្ទះលេខ ៥, ផ្លូវលេខ ៥៧, សង្កាត់បឹងកេងកង១, ខ័ណ្ឌចំការមន
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រលេខ ១១៧,
ទូរស័ព្ទ : (៨៥៥) ០២៣ ២១៤ ៩២៨
ទូរសារ : (៨៥៥) ០២៣ ២១៦ ២០៦
អ៊ីម៉ែល : director.kid@online.com.kh
គេហទំព័រ : http://www.online.com.kh/users/kid

www.kas.de/kambodscha

ផ្ទះលេខ ៤, ផ្លូវលេខ ៤៦២
ខណ្ឌចំការមន, ប្រអប់សំបុត្រ ៩៤៤
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

9 789995 088002